ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីក្នុង ឃុំសិរីមង្គល

## ឆ្នាំ ២០០៩-២០២២

## ស្រុកកូនមុំ ខេត្ត រតនគិរី



**រៀបចំដោយ:** គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ/សង្កាត់

**គាំទ្រដោយ:** សម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុក និងក្រុមសម្របសម្រួលស្រុក

ខែ ធ្នូ ឆ្នាំ ២០០៩

## មាតិកា


| | |
|---|---|
| **អារម្ភកថា** | ០៣ |
| **សេចក្តីផ្តើម** | ០៤ |
| **ជំពូក១: ព័ត៌មាន និងទិន្នន័យសំរាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ** | ០៥ |
| **១.១ ស្ថានភាពទូទៅ** | ០៥ |
| ១.១.១ ទីតាំងរដ្ឋបាល | ០៥ |
| ១.១.២ ប្រជាសាស្រ្ត | ៦ |
| ១.១.៣ ភាពគ្មានដីធ្លី | ៧ |
| ១.១.៤ ស្ថានភាពសេដ្ឋកិច្ច | ៨ |
| ១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ | ៨ |
| ១.១.៦ ស្ថានភាពសុខាភិបាល | ១០ |
| ១.១.៦.១ ផ្នែកសុខាភិបាល | ១០ |
| ១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត | ១១ |
| **១.២ ស្ថានភាពភូមិសាស្រ្ត** | ១១ |
| ១.២.១ ទីតាំងភូមិសាស្រ្ត | ១១ |
| ១.២.២ អាកាសធាតុ | ១៣ |
| ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន | ១៣ |
| **១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** | ១៤ |
| ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី | ១៤ |
| ១.៣.២ ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដី | ១៥ |
| ១.៣.៣ ស្ថានភាពកសិកម្ម | ១៧ |
| ១.៣.៤ ធនធានធម្មជាតិ | ២០ |
| ១.៣.៤.១ ធនធានព្រៃឈើ | ២០ |
| ១.៣.៤.២ ធនធានជលផល | ២០ |
| **១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល** | ២០ |
| ១.៤.១ ទីផ្សារ និងតំលៃកសិផល ផល-អនុផលព្រៃឈើ និងផលនេសាទ | ២០ |
| ១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល | ២១ |

១.៤.៣ ឱកាស និងឧបសគ្គ ២១
**ជំពូក២: ការវិភាគគំរូទការសំរាប់អនាគត** ២២
**២.១ តំបន់រសើប** ២២
**២.២ ការប្រឈម/ ឧបសគ្គ** ២២
**២.៣ គំរូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំ** ២៤
**២.៤ តំរូវការដីសំរាប់អនាគត** ២៥
២.៤.១ ប្រជាសាស្ត្រ ២៥
២.៤.១.១ អត្រាកំណើន ២៥
២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ ២៦
២.៤.២ តំរូវការដីសំរាប់លំនៅដ្ឋាន ២៧
២.៤.៣ តំរូវការដីកសិកម្ម ២៨
២.៤.៤ តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ២៨
២.៤.៥ តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម ២៩
២.៤.៥.១ តម្រូវការសាលារៀន ២៩
២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត ៣០
ក. សេវាកម្មសុខភាព ៣០
ខ. ការផ្គត់ផ្គង់ទឹកស្អាត ៣១
២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា ៣១
២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ៣២
**ជំពូក៣: ផែនការប្រើប្រាស់ដីពេលអនាគត ឆ្នាំ២០០៩ ដល់ ២០២២** ៣៤
**៣.១ ស្ថានភាពដី សក្តានុពលដី និងតំរូវការដី** ៣៤
៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល ៣៤
៣.១.២ តំរូវការដីតាមប្រភេទ ៣៤
**៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់** ៣៥
៣.២.១ ការវិភាគអន្តរអំពើ ៣៥
៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត ៣៦
៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី ៣៧

## អារម្ភកថា

របាយការណ៍ស្ដីអំពី ផែនការប្រើប្រាស់ដីនៅក្នុងឃុំសិរីមង្គលសំរាប់រយៈពេល ១៥ ឆ្នាំត្រូវបានរៀបចំឡើង ដោយក្រុមប្រឹក្សាឃុំ សិរីមង្គល និងមានការចូលរួមពីប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈដោយមានការ ចូលរួមជួយពីក្រុមអ្នកសម្របសម្រួលរៀបចំ ផែនការប្រើប្រាស់ដីធ្លី ស្រុកកូនមុំ ( D_LUP) សហការចូលរួមសម្របសម្រួលពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី ខេត្តរតនគិរី ( P_LUP ) និង គាំទ្របច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដី( Land Management Component) របស់អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ក្រោមការជួយឧបត្ថម្ភថវិកាពីអង្គការ DANIDA/ DFID-NZaid តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅក្នុងប្រទេសកម្ពុជា ។ គោលបំណងចំបងនៃផែនការប្រើប្រាស់ ដី នៅក្នុង ឃុំសេរីមង្គលនេះ គឺដើម្បីគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ និងសំរាប់ប្រើប្រាស់ក្នុងការ រៀបចំអភិវឌ្ឍន៍ ឃុំទាំងមូលឱ្យចំទិសដៅ និងឱ្យស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ សំដៅពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាលដើម្បីលើកស្ទួយសេដ្ឋកិច្ច និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ។

ក្រុមប្រឹក្សាឃុំសេរីមង្គលសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងអង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅក្នុងប្រទេសកម្ពុជា ដែលបានផ្ដល់ថវិកាជំនួយសំរាប់ដំណើរការរៀបចំផែនការប្រើប្រាស់ដីនេះចាប់តាំងពីការចាប់ផ្ដើមរហូតដល់ទីបញ្ចប់ ។ ជាមួយគ្នានេះដែរ ក៏សូមថ្លែងអំណរគុណផងដែរ ដល់ក្រុមការងាររបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តរតនគិរី ដែលបានជួយសម្របសម្រួលក្នុងការរៀបចំផែនការនេះ ហើយផែនការនេះ ក៏អាចនឹងមិនទទួលបានភាពជោគជ័យផងដែរ ការចូលរួមពីមន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ជាពិសេសអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត រដ្ឋបាលព្រៃឈើ មន្ទីរកសិកម្មខេត្ត និងមន្ទីរបរិស្ថានខេត្ត ។

ក្រុមប្រឹក្សាឃុំសេរីមង្គល ក៏មិនអាចបំភ្លេចបានផងដែរ នូវការជួយឧបត្ថម្ភ គាំទ្រ បង្ហាត់បង្ហាញទាំងទ្រឹស្ដី និងបច្ចេកទេសអនុវត្តផ្ទាល់លើការងាររៀបចំផែនការប្រើប្រាស់ដីធ្លី ពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីធ្លីថ្នាក់ខេត្ត ( P_LUP ) ថ្នាក់ស្រុក (D_LUP) និងក្រុមការងារថ្នាក់ជាតិ របស់សមាសភាគរៀបចំដែនដី ។

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថា សម្ដេច ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់នឹងបានយល់ដឹងអំពី ស្ថានភាព និងតម្រូវការ ព្រមទាំងបញ្ហាប្រឈមទាំងឡាយពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លី ដែលរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍ឃុំសេរីមង្គលហើយ នឹង បង្ហាញនូវទឹកចិត្តសម្បុរសធម៌ដ៏ថ្លៃថ្លា តាមរយៈការចូលរួមផ្ដល់នូវសំភារៈ និង ថវិការសំរាប់គាំទ្រការអនុវត្តន៍ផែនការប្រើប្រាស់ដីធ្លីនេះ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍មូលដ្ឋាន តាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ។

សិរីមង្គល, ថ្ងៃទី..02....ខែ...04......ឆ្នាំ ២០10

មេឃុំ

មិន~ស្រ៊ុន

## សេចក្តីផ្តើម

ឃុំសិរីមង្គល ស្រុកកូនមុំ ខេត្តរតនគិរី ស្ថិតនៅជាប់ទន្លេស្រែពកប៉ែកខាងត្បូងមានចំងាយពីទីរួមស្រុកកូនមុំ ២២ គីឡូម៉ែត្របើគិតពីក្រុងបានលុងមកឃុំមានចំងាយ ៦២គីឡូម៉ែត្រ ។ ឃុំសិរីមង្គលស្ថិតនៅខាងត្បូងឈៀងខាងកើត នៃទីរួមស្រុក ។ប្រជាជនរស់នៅភាគច្រើន មានមុខរបរ ធ្វើកសិកម្ម ( ធ្វើស្រែ ៧0% ,ធ្វើចំការ ១0%) នេសាទ( ១៥%) និងរកអនុផលព្រៃឈើ( ៥%) ដើម្បីចិញ្ចឹមជីវិត ។ ដោយពិនិត្យស្ថានភាពជាក់ស្តែងនៃឃុំសិរីមង្គល ជាឃុំជាប់ដងទន្លេស្រែពក ធ្វើអោយពួកគាត់មានការជួបប្រទះការលំបាកទៅលើ គ្រោះទឹកជំនន់ដែលធ្វើអោយលិចលង់បណ្តាលអោយមានការផ្លាស់ប្តូរលំនៅដ្ឋានទៅរកទីទួលខ្ពស់ៗ រស់នៅបណ្តោះអាសន្ន ដើម្បីរងចាំពេលទឹកស្រកទៅវិញ ។ ម្យ៉ាងទៀតការប៉ះពាល់ដ៏ធំ គឺមានការខូចខាតភោគផលដំណាំ ផ្ទះសំបែង ចំណែកផ្លូវគមនាគមន៍មិនទាន់មានលក្ខណៈ ល្អប្រសើរនៅឡើយ ចំណែកការការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ មិនទាន់ច្បាស់លាស់ ជាហេតុធ្វើ អោយក្រុមប្រឹក្សាឃុំ និង សមាជិក គ.ថ.ផ ប្រជាជនក្នុងឃុំមានគោលបំណងបង្កើតផែនការប្រើប្រាស់ដីឃុំស្របច្បាប់ប្រកបដោយតម្លាភាព និង ប្រសិទ្ធិភាពខ្ពស់ ។

ផែនការប្រើប្រាស់ដីបើនិយាយជារួមបានឆ្លុះបញ្ចាំងពីបញ្ហា និងតំរូវការចាំបាច់របស់ ប្រជាពលរដ្ឋលើវិស័យទាំងប្រាំដូចជាសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និង បរិស្ថាន ផ្នែកសេវាកម្មរដ្ឋបាល និង សន្តិសុខ ផ្នែកយេនឌ័រ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអទិភាពទាំងនេះក្នុងការចូលរួមចំណែកលើកកំពស់ជីវភាពរស់នៅ និងសុខភាព របស់ប្រជាពលរដ្ឋអោយកាន់តែល្អប្រសើរឡើងជាងមុន បើនិយាយជារួមវិញផែនការប្រើប្រាស់ដីឃុំជាឧបករណ៍មួយដ៏ សំខាន់ដែលជួយដល់ក្រុមប្រឹក្សាឃុំ ក៏ដូចជាខេត្តទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង និង ប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចិរភាព និង ប្រសិទ្ធិភាព ។ ដូច្នេះការប្រើប្រាស់ដីឃុំជាការងារស្នូល សំរាប់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ពិសេសអាជ្ញាធរដែនដី និងមានមូលដ្ឋានអោយកាន់តែគ្រប់ជ្រុងជ្រោយក្នុងការរៀបចំ បញ្ចូលផែនការប្រើប្រាស់ដីនៅក្នុងផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ចនៅថ្នាក់មូលដ្ឋានដោយធ្វើសមាហរកម្មផែនការថ្នាក់ស្រុក និង ការអនុម័តក្នុងការកសាងផែនការ អភិវឌ្ឍន៍សេដ្ឋកិច្ចដោយមានការចូលរួម ពីគ្រប់ភាគីពាក់ព័ន្ធក្នុងការចូលរួម សេដ្ឋកិច្ច ។

# ជំពូកទី១
# ព័ត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

## ១.១ ស្ថានភាពទូទៅ

ឃុំសិរីមង្គលកាលពីដើមឡើយ គឺគ្មានមនុស្សរស់នៅទេ ព្រោះឃុំនេះ នៅឆ្ងាយដាច់ស្រយាលធ្វើអោយមនុស្សម្នាពិបាកទៅរស់នៅទីនោះ តែក្រោយមកមានយាយម្នាក់ឈ្មោះ យាយពក គាត់បានមករស់នៅទីនោះ ហើយបានបង្កើតភូមិ ១ ឈ្មោះថាភូមិស្រែពកធំ ។ ការរស់នៅក្នុងភូមិស្រែពកកាលនោះមានមនុស្ស ៥ ទៅ ៦ គ្រួសារហើយបានរស់នៅបង្កើតបានជាកូនចៅច្រើនទៅៗ យាយបានរួមយោបល់ជាមួយអ្នកដែលរស់នៅក្នុងភូមិ ហើយបានបំបែកភូមិនោះជាពីរ គឺភូមិស្រែពកតូច និងភូមិនាងដី ។

ក្រោយថ្ងៃរំដោះក្នុងឆ្នាំ ១៩៧៩ មកកាលនោះរណសិរ្សរួបរួមជាតិបានរួមទាំង ៣ភូមិ បង្កើតដាក់ឈ្មោះថាឃុំ *សិរីមង្គល*ហើយអ្នកដែលបង្កើតឃុំនោះគឺលោកតាខាំហ្មុត ហើយឃុំសិរីមង្គលបានជាប់ឈ្មោះរហូតមកដល់សព្វថ្ងៃនេះ។

### ១.១.១ ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| **ខេត្ត** | **រតនៈគីរី** | |
| **ស្រុក/ក្រុង** | **កូនមុំ** | |
| **ឃុំ/សង្កាត់** | **ឈ្មោះ:** សិរីមង្គល | **លេខកូដ:** ១៦០៤០១ |
| **ចំនួនភូមិ** | **៣ ភូមិ ក្នុងនោះមាន :** នាងដី,ស្រែពកធំ,ស្រែពកតូច | |

ឃុំសិរីមង្គល ស្ថិតនៅជាប់ទន្លេស្រែពកប៉ែកខាងត្បូងមានចំងាយពីទីរួមស្រុកកូនមុំ ២២ គីឡូម៉ែត្រ បើគិតពីក្រុងបានលុងមកឃុំមានចំងាយ ៦២ គីឡូម៉ែត្រ។ ឃុំនេះមានព្រំប្រទល់ខាងលិចជាប់ឃុំស្រែអង្គ្រង ខាងកើតជាប់ស្រុកលំផាត់ ខាងជើងជាប់ឃុំត្រពាំងច្រេស និង ខាងត្បូងជាប់ខេត្តមណ្ឌលគិរី ។ ឃុំសិរីមង្គលមានក្រឡាផ្ទៃចំនួន ៥៤ ៥៤៣ ហិកតា ចែកចេញជាភូមិ ចំនួន ០៣ ដែលស្ថិតនៅតាមដងទន្លេស្រែពក ។




**រូបភាពទី ១ :** ផែនទីតាំងរដ្ឋបាល

### ១.១.២ ប្រជាសាស្ត្រ

ឃុំសិរីមង្គល មានប្រជាជនសរុបចំនួន ៣៤៧ គ្រួសារ ប្រជាជនចំនួន ១៦០១ នាក់ ក្នុងនោះស្ត្រី ៨៧៣នាក់ មានដង់ស៊ីតេ ៣៤.០៩ នាក់ក្នុង១គីឡូម៉ែត្រក្រឡា។ របាយប្រជាជន នៅបណ្តាភូមិខាងទាំង ៣ ខាងលើ ភូមិស្រែពកធំ មានចំនួនប្រជាជន ៩២៤នាក់ ភូមិស្រែពកតូចមានចំនួនប្រជាជន ៥២៥ នាក់ ភូមិនាងជីមានចំនួនប្រជាជន ១៥១នាក់។ ឃុំសិរីមង្គលភាគច្រើនជាជនជាតិខ្មែរឡាវ ជាទូទៅប្រជាជនទាំងអស់កាន់ព្រះពុទ្ធសាសនា តែក៏នៅមានជំនឿទៅលើការសែនព្រេនអារក្ខអ្នកតាខ្លះដែរ ។

<u>តារាងស្ថិតិប្រជាជនឃុំសិរីមង្គល ឆ្នាំ២០០៨ តាមក្រុមអាយុ</u>

| ស្ថិតិតាមក្រុមអាយុ | ប្រុស | ស្រី | សរុប | ផ្សេងៗ |
|---|---|---|---|---|
| អាយុក្រោម០៥ឆ្នាំ | ៦៥ | ៨៩ | ១៥៤ | |
| អាយុ ០៥ឆ្នាំ | ៥០ | ៥៥ | ១០៤ | អាយុចូលរៀនមត្តេយ្យ |
| អាយុពី ៦-១១ឆ្នាំ | ៩៣ | ១១៣ | ២០៦ | អាយុចូលរៀនបឋមសិក្សា |
| អាយុពី ១២-១៤ឆ្នាំ | ៦៤ | ៥៩ | ១២៣ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី ១៥-១៧ឆ្នាំ | ៥៥ | ៦៩ | ១២៤ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ឆ្នាំ | ៩៦ | ១១៩ | ២១៥ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី ២៥-៦០ឆ្នាំ | ២៦១ | ៣២១ | ៥៨២ | អាយុពេញពលកម្ម |
| អាយុពី ៦១ឆ្នាំឡើងទៅ | ៤៤ | ៤៨ | ៩២ | អាយុចូលនិវត្តន៍ |
| ប្រជាជនសរុប | **៧២៨** | **៨៧៣** | **១៦០១** | |
| ចំនួនគ្រួសារសរុប | **៣៤៧** | | | |

## ១.១.៣ ភាពគ្មានដីធ្លី

- គ្រួសារគ្មានដីស្រែផ្ទាល់ខ្លួន ២៦គ្រួសារ គ្រួសារប្រភេទនេះបច្ចុប្បន្ន ត្រូវបានប្រកបរបរ ដោយការ ស៊ីឈ្នួល ដកស្ទូង ច្រូតស្រូវ រកអនុផលព្រៃឈើ ចិញ្ចឹមសត្វ នេសាទតាមដងទន្លេស្រែពក ដើម្បីដោះស្រាយជីវភាព ។
- គ្រួសារមានដីស្រែតិចជាង ០១ហិកតា : ៣០គ្រួសារ គ្រួសារទាំងនេះក៏ត្រូវរកចំណូលបន្ថែមទើបអាចហូបចុក គ្រប់គ្រាន់ ដែលក្នុងនោះពួកគាត់ត្រូវ ស៊ីឈ្នួល ដកស្ទូង រកនេសាទ ចិញ្ចឹមសត្វ និងអនុផលព្រៃឈើ ដើម្បី បំពេញការទិញអង្ករហូបនៅរដូវវស្សា គ្រួសារប្រភេទនេះមានអ្នកខ្លះមានគោ ក្របី និងឧបករណ៍នេសាទដើម្បី ជួយដល់ជីវភាពរបស់ពួកគាត់ ។

<u>តារាងចំនួនគ្រួសារដែលគ្មានដី និងមានដីមិនគ្រប់គ្រាន់</u>

| លរ | បរិយាយ | ចំនួនគ្រួសារ | ភាគរយ/ប្រជ.សរុប | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្មានដីស្រែផ្ទាល់ខ្លួន | ២៦ | ៧.៥១% | |
| ២ | មានដីស្រែតិចជាង ១ ហិកតា | ៣០ | ៨.៦៧% | |

### ១.១.៤ ស្ថានភាពសេដ្ឋកិច្ច

ឃុំសិរីមង្គលជាឃុំមួយដែលស្ថិតនៅជាប់មាត់ទន្លេស្រែពកក្រោមការគ្រប់គ្រងរបស់ស្រុកកូនមុំ។ ប្រជាជននៅក្នុងឃុំនេះភាគច្រើនប្រកបមុខរបរធ្វើស្រែចំការ ក្នុង១ឆ្នាំតែមួយវស្សាប៉ុណ្ណោះ ដែលជាចំណូលសំខាន់ តែនៅមានមុខរបរបន្ទាប់បន្សំដូចជានេសាទត្រី ការបរបាញ់សត្វ រកជ័រ ការលក់ដូរតាមផ្ទះតិចតួច ហើយចំពោះការដោះដូរលុយកាក់ ឬសំភារៈផ្សេងៗ ប្រជាជននៅក្នុងឃុំត្រូវឡើងមកទីរួមស្រុក រឺក្រុង។ ក្រៅពីមុខរបរធ្វើស្រែ ចំការ ប្រជាជនមានការពឹងពាក់ទៅលើព្រៃឈើ និងផលនេសាទដូចជាការ បោចវល្លិ ផ្តៅ ជ័រទឹក ជ័រចុង ផ្សិត និងបន្លែបង្ការព្រៃ រុករកចាប់សត្វដូចជា អណ្តើក ត្រកួត និងការនេសាទត្រី។ លើសពីនេះក៏នៅមានឈើសំណង់ ដែលផ្គត់ផ្គង់សំរាប់ការសាងសង់សំណង់ផ្សេងៗក្នុងទីរួមខេត្តទៀតផង។

តែឃុំក៏មានបញ្ហា ដែលឃុំតែងតែ ជួបប្រទះ ជាញឹកញាប់នោះគឺគ្រោះទឹកជំនន់ ដែលធ្វើអោយលិចលង់បណ្តាលអោយមានការខូចខាតភោគផលដំណាំ ផ្ទះសំបែង ចំណែកឯផ្លូវគមនាគមន៏ក៏មិនទាន់ល្អប្រសើរនៅឡើយ ។

<u>តារាងមុខរបបរសំខាន់ៗរបស់ប្រជាជនឃុំសិរីមង្គល</u>

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | | ផ្សេងៗ |
|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | |
| ១ | **មុរបរកសិកម្ម** | | | |
| | ធ្វើស្រែជាចំបង | ៣៤៦ | ៩៩.៧១ | ស្រែវស្សា |
| | ដាំដំណាំរយៈពេលវែងជាចំបង | ១ | ០,២៩ | ស្វាយ,ដូង, ខ្នុរ,....... |

### ១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ

ឃុំសិរីមង្គលមានកំរិតនៃការសិក្សាដល់ ត្រឹមបឋមសិក្សា មានសាលារៀនចំនួន ៣ ដែលមាន ៩បន្ទប់ ស្មើនឹង ៦ថ្នាក់ មានគ្រូបង្រៀនចំនួន ១០ នាក់ បច្ចុប្បន្នតាមព័តិមានសៀវភៅស្ថានភាពភូមិបានបង្ហាញអោយឃើញថានៅក្នុងឃុំសិរីមង្គលកុមារចាប់ពីអាយុ ៦ឆ្នាំបានចូលរៀនមានចំនួន ៣១ នាក់ ស្មើនឹង៤៣.៦៦% និងមិនបានចូលរៀន ៤០ នាក់ ស្មើនឹង ៥៦.៣៤% និងកុមារអាយុចាប់ពី ៦-១១ឆ្នាំ បានចូលរៀនមានចំនួន ១៦០ នាក់ ស្មើនឹង ៧៧.២៩ % និងមិនបានចូលរៀនមានចំនួន ៤៧ នាក់ ស្មើនឹង ២២.៧១ % ចំណែកសិស្សអាយុពី ១២-១៤ ឆ្នាំកំពុងចូលរៀន មានចំនួន ១២១ នាក់ស្មើ ៩៨.៣៧% និងមិនបានចូលរៀន ២នាក់ ស្មើនឹង ១.៦៣%។ និងអនក្ខរជន ដែលមានអាយុពី ១៥-១៧ ឆ្នាំឡើងមានរហូតដល់ ៦០.៤៨% គឺជាចំនួនមួយបើប្រៀបធៀបទៅនឹងចំនួនយុវជនក្នុងឃុំសរុបស្មើរនឹង ១២៤ នាក់ ។ មូលហេតុខាងលើតាមការសាកសួរក្រុមប្រឹក្សាឃុំ និងប្រជាជនបានអោយដឹងថាកុមារដែលមិនបានចូលរៀន និងកុមារ

ដែលបោះបង់ការសិក្សា ដោយសារកុមារទាំងនោះមួយចំនួនតាមឪពុកម្តាយ ទៅប្រកបការងារធ្វើស្រែចំការនៅឆ្ងាយពីផ្ទះ និងមួយចំនួនទៀតជួយធ្វើការងារឪពុកម្តាយនៅផ្ទះ ។

ទន្ទឹមនោះដែរបច្ចុប្បន្នមានការខ្វះខាតគ្រូបង្រៀន និងខ្វះសាលារៀនចាប់ពីកំរិតបឋមសិក្សា ដល់វិទ្យាល័យ ។ ឯសាលាបឋមសិក្សាមាន ទីតាំងគ្រប់គ្រាន់ តែនៅលើទីតាំងនីមួយៗ មានការខ្វះខាតអាគារសិក្សា ដែលទាមទារត្រូវមានការសាងសង់បន្ថែម ចំណែកសាលាមតេយ្យមានវិធានការ បង្កើតឱ្យបាននៅគ្រប់ភូមិ ដែលបច្ចុប្បន្នពុំទាន់មាននៅឡើយ ។

តារាង ស្ថិតិសាលា និងចំនួនសិស្ស ប្រចាំឆ្នាំ ២០០៨

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | អត្រាមិនចូលរៀន |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារសរុប | សិស្សសរុប | សិស្សស្រី | |
| ថ្នាក់មត្តេយ្យសិក្សា | ០ | ០ | ០ | ១០៤ | ០ | ០ | ១០០ |
| ថ្នាក់បឋមសិក្សា | ៣ | ៩ | ៦ | ២០៦ | ១៦០ | ៩៣ | ២២ |
| ថ្នាក់អនុវិទ្យាល័យ | ០ | ០ | ០ | ១២៣ | ១២១ | ៥៧ | ២ |




**រូបភាពទី ២ :** (សាលាបឋមសិក្សាស្រែពកធំ)

## ១.១.៦ ស្ថានភាពសុខាភិបាល

### ១.១.៦.១ ផ្នែកសុខាភិបាល

ឃុំសិរីមង្គលមានសេវាសុខភាព ១ កន្លែង ស្ថិតនៅភូមិស្រែពកធំ បើគិតពីចំងាយផ្លូវពីភូមិនិមួយៗមក ប៉ុស្តិ៍សុខភាពមានចំងាយ៨គីឡូម៉ែត្រ ជាមធ្យមបច្ចុប្បន្នប៉ុស្តិ៍សុខភាពនោះមានគ្រូពេទ្យចំនួន ០២នាក់ និង ពេទ្យឆ្មប ០១នាក់ ដោយឡែកឃុំសិរីមង្គលក៏មានគ្រូពេទ្យបុរាណនៅតាមភូមិមួយចំនួនផងដែរ។ ចំពោះសេវាសុខភាព នៅក្នុងឃុំនេះពុំទាន់បានបំពេញនៅសេចក្តីត្រូវការរបស់ប្រជាជនទូទាំងឃុំនៅឡើយព្រោះមិនមានគ្រូពេទ្យប្រចាំការសំរាប់ថែទាំសុខភាពគ្រប់គ្រាន់នៅឡើយ ម៉្យាងទៀត គ្រូពេទ្យដែលបំរើការងារសព្វថ្ងៃ ជំនាញគឺនៅមានកំរិត រីឯសេវាផ្សព្វផ្សាយពីការថែទាំសុខភាព មិនទាន់បានទូលំទូលាយ កត្តានេះហើយបានធ្វើអោយប្រជាជន មួយចំនួនគាត់មិនបានចូលរួម ប្រើប្រាស់ សេវាសុខភាពទេ។អ្នកភូមិ មួយចំនួននៅពេលគាត់មានជំងឺធ្ងន់ធ្ងរពួកគាត់តែងតែមានការកាប់ ជ្រូក ឬមាន់ដើម្បី សែនព្រេន អ្នកភូមិខ្លះទៀតក៏ មកព្យា បាលនៅពេទ្យខេត្តដែលមានចំងាយផ្លូវ ៦២ គីឡូម៉ែត្រ និង ពិបាកក្នុងការធ្វើដំណើរ។

ផ្អែកទៅតាមស្ថានភាពភូមិសាស្ត្រនៃឃុំសិរីមង្គល ដែលមានប្រជាជនរស់នៅតាមភូមិដាច់ឆ្ងាយពីគ្នា និងមានចំងាយផ្លូវឆ្ងាយពីប៉ុស្តិ៍សុខភាពឃុំបណ្តាលអោយមានការលំបាកក្នុងការធ្វើដំណើរ ដូច្នេះការផ្តល់សេវាកម្មផ្នែកសុខភាពមិនទាន់គ្រាប់គ្រាន់ ។ ស្ថិតក្នុងដំណាក់កាលនេះឃុំសិរីមង្គល ក៏ពុំទាន់មាន ប៉ុស្តិសុខភាព នៅតាមភូមិសំរាប់ ជួយសំរួលដល់ការទ្រទ្រង់ សុខមាលភាព របស់ប្រជាពលរដ្ឋ បន្ថែមលើមណ្ឌលសុខភាពស្រុកនៅឡើយទេ ។

<u>តារាងស្ថិតិមណ្ឌល/ប៉ុស្តសុខភាព និងចំនួនគ្រូពេទ្យ</u>

| ល.រ | មណ្ឌល/ប៉ុស្តិសុខភាព | សមត្ថភាពផ្គត់ផ្គង់សេវាកម្ម | | | | |
|---|---|---|---|---|---|---|
| | | ចំនួន | គ្រែ/បន្ទប់ | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណ |
| ១ | ប៉ុស្តិ៍សុខភាព | ០១ | ៣ | ២ | ១ | ២ |
| ២ | ប៉ុស្តិសុខភាពភូមិ | ០ | ០ | ០ | ០ | ០ |




**រូបភាព ៣** :ប៉ុស្តិ៍សុខភាពសិរីមង្គល

### ១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត

ចំពោះសេវានៃការប្រើប្រាស់ទឹកស្អាតប្រជាជននៅក្នុងឃុំសិរីមង្គលបច្ចុប្បន្នភាគច្រើនមិនទំលាប់ប្រើប្រាស់ទឹកអណ្តូងទេ ប្រជាជននៅក្នុងឃុំពួកគាត់ប្រើប្រាស់ទឹកទន្លេស្រែពក សំរាប់ធ្វើការដាំស្ល និងសំរាប់បរិភោគ ។

## ១.២. ស្ថានភាពភូមិសាស្រ្ត

### ១.២.១ ទីតាំងភូមិសាស្រ្ត

ភូមិសាស្រ្តឃុំសិរីមង្គលមានរាងទ្រវែង បណ្តោយពីជើងមកត្បូងប្រមាណជា ៤២២៨៣ម៉ែត្រ និង ទទឹងពីលិចមកកើតត្រង់ចំណុចពាក់កណ្តាលប្រមាណជា ១៥៣៥៣ម៉ែត្រ ហើយផ្នែកជើងមានរៀងស្តួចដែល មានទទឹងពីលិចទៅកើតប្រមាណជា ៨៩៥២ ម៉ែត្រ លាតសន្ធឹងយ៉ាងវែង ផ្នែកខាងកើតនៃឃុំស្ថិតនៅជាប់ និង ឃុំជ័យឧត្តម ស្រុកលំផាត់ នឹងខាងជើងជាប់ឃុំ ត្រពាំងច្រេស ខាងលិចជាប់ និងឃុំស្រែអង្រ្កង ផ្នែកខាងត្បូងនៃឃុំស្ថិត នៅជាប់ស្រុកកោះញែក របស់ខេត្តមណ្ឌលគិរី ។

ផ្ទៃដីឃុំទាំងមូលតំបន់នេះភាគច្រើនរាលទំនាប និងខ្ពង់រាបបន្តិចបន្តួច មានរយៈ កំពស់ពី ៨២ម៉ែត្រ ដល់ ៤០២ម៉ែត្រ នៅផ្ទៃកកណ្តាលនៃសណ្ឋានដីរបស់ឃុំជាតំបន់មានលក្ខណៈជាទីជំរាល ដែលមានផ្លូវទឹកយ៉ាងខ្វាត់ខ្វែងហូរចាកមកទន្លេ ស្រែពក។




**រូបភាពទី ៤ :** ផែនទីរយៈកំពស់

## ១.២.២ អាកាសធាតុ

យោងតាមកំណត់ត្រា របស់នាយកដ្ឋានឧត្តុនិយមនៃក្រសួងធនធានទឹក និងឧត្តុនិយម ពីឆ្នាំ ២០០៣-២០០៦ បង្ហាញអោយឃើញថា កំពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំខ្ពស់ជាងគេ ២៧៩១.៧មម នៅឆ្នាំ ២០០៦ ហើយទាបជាងគេ ២១១៩.៨មម នៅឆ្នាំ២០០៤។ ភ្លៀងធ្លាក់ច្រើននៅរដូវវស្សាចាប់ពីខែ ឧសភា ដល់ខែកញ្ញា ដែលកំពស់ទឹកភ្លៀងមធ្យមពី ១៧២.០-៧៤៦.៧មម។

រយៈពេលនៃរដូវប្រាំង៖ ៦ ខែ គឺចាប់ពីខែ ធ្នូ ដល់ខែ មេសា និងរយៈពេលនៃរដូវវស្សា ពីខែ ឧសភា ដល់ ខែ តុលា ហើយចំពោះការប្រែប្រួលមានលំអៀងតិចតួចប៉ុណ្ណោះ ដោយជួនកាលអាចរាំងតាំងពីពាក់កណ្តាល ខែធ្នូ។




| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| " 2003" | 0.0 | 0.0 | 90.8 | 121.0 | 390.2 | 287.1 | 480.3 | 396.6 | 452.7 | 77.6 | 55.6 | 0.0 |
| " 2004" | 0.0 | 0.0 | 48.6 | 23.8 | 172.0 | 511.1 | 413.8 | 509.4 | 400.5 | 32.6 | 8.0 | 0.0 |
| "2005" | 0.0 | 0.0 | 6.4 | 48.8 | 195.7 | 300.9 | 643.6 | 746.7 | 408.5 | 128.4 | 13.6 | 7.4 |
| " 2006" | 0.0 | 0.0 | 0.0 | 147.2 | 317.6 | 212.2 | 682.9 | 642.0 | 504.5 | 257.6 | 0.0 | 27.7 |

**រូបភាព ០៥:** ក្រាភិច របាយទឹកភ្លៀងមធ្យមប្រចាំឆ្នាំ ខេត្តរតនគិរី

## ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

មានផ្លូវក្រាលគ្រួសក្រហមតភ្ជាប់មកពីទីរួមស្រុកកូនមុំ មកដល់មាត់ទន្លេស្រែពក ដែលមានចម្ងាយប្រមាណ ២២គម. នេះជាហេដ្ឋារចនាសម្ព័ន្ធផ្លូវគោកយ៉ាងសំខាន់ ដោយឡែកតាមផ្លូវទឹកក៏មានសារៈសំខាន់ក្នុងការដឹកជញ្ជូនដែរ តែស្ថានភាពទន្លេមិនអំណោយផលឱ្យទូក កាណូតធំៗចេញចូលបានទេ ទូកដែលអាចធ្វើចរាចរបានតាមដងទន្លេ នេះ គឺអាចដឹកបានត្រឹមតែចំណុះកន្លះតោន ទៅ១តោន នៅរដូវវស្សាតែប៉ុណ្ណោះការធ្វើដំណើរ និងការដឹកជញ្ជូនតាមផ្លូវទឹក ភាគច្រើនគឺតភ្ជាប់ពីឃុំទៅកាន់ខេត្តស្ទឹងត្រែង។



**រូបភាពទី ៦ :**ផ្លូវលំជនបទ ផ្លូវចូលឃុំសិរីមង្គល

## ១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី

ក្នុងឃុំសិរីមង្គលមានចំណាត់ថ្នាក់នៃការប្រើប្រាស់ដីលំអិតចំនួន ១៣ប្រភេទ រួមមានដីលំនៅដ្ឋានភូមិ ( ផ្ទះ-ឈើហូបផ្លែ) កន្លែងកប់ខ្មោច(ដីកន្លែងកប់ខ្មោច) ស្រូវវស្សា ដីកសិកម្មពនេចរ ( ដីចំការផ្លាស់វេន ) ព្រៃស្រោងស្ងួត (ព្រៃញាតមាន ឈើធំៗ) ព្រៃល្បោះ ព្រៃល្បោះស្ងួត ព្រៃចំរុះ(ស្រោង និងរបោះ) ព្រៃដុះឡើងវិញ ( ព្រៃកម្ពោធ )វាលស្មៅ (ស្រែបោះបង់) ចំការបោះបង់ដុះស្មៅ (ព្រៃបូស) ព្រៃគម្ពោធ ចំការបោះបង់ដុះព្រៃគម្ពោធព្រៃគម្ពោធលាយដើមឈើ ធំមួយៗ បឹង អូរ-ស្ទឹង-ទន្លេ វាលភក់ និងប្រភេទនៃការប្រើប្រាស់ដីសាមញ្ញ ០៤ប្រភេទរួមមាន ដីកសិកម្ម ដីព្រៃឈើ ដីវាលស្មៅនិងស្បូវ និងប្រភពទឹក ។

**<u>តារាងប្រភេទនៃការប្រើប្រាស់ដីលំអិត</u>**

| លរ | ប្រភេទនៃការប្រើប្រាស់ដី | ក្រឡាផ្ទៃ | | ចំណាត់ថ្នាក់របស់មូលដ្ឋាន |
|---|---|---|---|---|
| | | ម$^2$ | ហិចតា | |
| ០១ | ដីលំនៅដ្ឋាន | ៣៦២០១៥ | ៣៦ | ដីលំនៅដ្ឋាន |
| ០២ | ស្រូវវស្សា | ៧២៦៤៧៥ | ៧២៦ | ស្រូវវស្សា |
| ០៣ | ដីកសិកម្មពនេចរ | ៦៥៤៣៦៩ | ៦៦ | ដីចំការផ្លាស់វេន |

| | | | | |
|---|---|---|---|---|
| ០៤ | ព្រៃរបោះ | ៣៦៣៨០៥៦៥៦ | ៣៦៣៨១ | ព្រៃរបោះ |
| ០៥ | ព្រៃស្រោងស្ងួត | ៤៩០៩២៩៦៩ | ៤៩០៩ | ព្រៃញៀតមានឈើធំៗដុះច្រើន |
| ០៦ | ព្រៃស្រោងសើម | ៦៤២៣១៣៩ | ៦៤៣ | ព្រៃញៀតមានឈើធំៗដុះមួយៗ |
| ០៧ | ព្រៃចំរុះ(ស្រោង និងរបោះ) | ៣៨៦១៥១៤៨ | ៣៨៦១ | ព្រៃចំរុះ(ស្រោង និងរបោះ) |
| ០៨ | ព្រៃដុះតាមមាត់ទឹក(អូរ ស្ទឹង) | ៥០៤៨០០២៤ | ៥០៤៨ | ព្រៃដុះតាមមាត់ទឹក(អូរ ស្ទឹង) |
| ០៩ | វាលភក់ | ៥០៧៤១៨៣ | ៥០៧ | វាលភក់ |
| ១០ | បឹង | ៣២៣៦៤ | ១៤ | បឹង |
| ១១ | ទន្លេ ស្ទឹង អូរ | ២៧៧៨៨៤៥ | ២៧៧ | ទន្លេ ស្ទឹង អូរ |
| ១២ | ព្រៃដុះឡើងវិញ | ១១៥៦២៧២៩ | ១១៥៦ | ព្រៃកម្ពោច |
| ១៣ | ព្រៃកម្ពោចលាយដើមឈើធំមួយៗ | ៨៩១៨១៦៥ | ៨៩២ | ព្រៃកម្ពោចលាយដើមឈើធំមួយៗ |
| ១៤ | វាលស្មៅ | ២៦៦៧២៣ | ២៧ | វាលស្មៅ |
| **សរុប** | | **៩៤៥៣៣០៨០៤** | **៩៤៥៤៣** | |

ប្រភព :(លំអិតអំពីប្រភេទនៃការប្រើប្រាស់ដីនីមួយៗ មានពិពិណនាលំអិតនៅក្នុងឧបសម្ព័ន្ធ ១ និងមានភ្ជាប់ជាមួយនូវផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញ ខ្នាត អា៣)

## ១.៣.២ ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដី

ក្នុងឃុំទាំងមូល បើនិយាយអំពីកម្មសិទ្ធិដីរបស់ប្រជាពលរដ្ឋ គឺមិនទាន់មានការចុះបញ្ជី និងការចេញប័ណ្ណ សំគាល់អចលនវត្ថុជូនដល់ប្រជាពលរដ្ឋនៅឡើយទេ តែចំពោះដីកសិកម្មពនេចរ គឺពួកគាត់មានការគ្រប់គ្រង និងកាន់ កាប់តាមបែបប្រពៃណី។ បច្ចុប្បន្នដោយសារមានអ្នកចំណូលថ្មីច្រើនចូលទៅតាំងទីលំនៅក្នុងឃុំនោះ ការទិញលក់ដី ក៏កើតមានតិចតួចដែរ តែពុំមានរូបភាពធំដុំទេ។ ការកាប់រានយកដីក៏កើតមានជារូបភាពតូចតាច ដែលភាគច្រើនគឺកើត មានឡើងតាមបណ្តោយផ្លូវគ្រួសក្រហមដែលមានលក្ខណៈងាយស្រួលក្នុងការធ្វើចរាចរ។ និយាយរួមក្រៅពីដីលំនៅដ្ឋាន គឺមានដែនជំរកសត្វព្រៃលំផាត់ ដែលក្រឡាផ្ទៃទំហំ ៤៣៤១៨ ហិកតា ហើយតំបន់នេះ ស្ទើរតែគ្របដណ្តប់ទាំងអស់នៃផ្ទៃដីឃុំប្រមាណជាង ៧០% ដែលជាដីសាធារណៈរបស់រដ្ឋ ហើយបានចេញដោយព្រះរាជក្រិត្យ។

<u>តារាងសង្ខេបស្ថានភាពកាប់កាប់និងគ្រប់គ្រងដី</u>

| **លរ** | **ប្រភេទនៃការគ្រប់គ្រង** | **ទំហំដី (ហត)** | **ផ្សេងៗ** |
|---|---|---|---|
| ១ | តំបន់ជំរកសត្វព្រៃលំផាត់ | ៤៣៤១៨ | តំបន់នេះត្រូវបាន ការពារសត្វព្រៃគ្រប់ប្រភេទ និងបរិស្ថានហើយមានការគ្រប់គ្រងដោយបរិស្ថាន ។ |
| | ព្រៃរបោះ | ២៨៣៦៤ | ៤៥ កន្លែង |

| | | | |
|---|---|---|---|
| | ព្រៃស្រោងស្ងួត | ៤៥១១ | ២១ កន្លែង |
| | ព្រៃស្រោងសើម | ៩៧ | ៩ កន្លែង |
| | វាលស្មៅ | ២៤ | ៤ កន្លែង |
| | វាលភក់ | ២៧៧ | ១៨ កន្លែង |
| | ព្រៃចំរុះ | ៣៨៤៤ | ៩ កន្លែង |
| | ព្រៃដុះតាមមាត់ទឹក | ៤៨៣៦ | ១៥ កន្លែង |
| | ទន្លេ ស្ទឹង អូរ | ១៦៥ | ១ កន្លែង |
| | ព្រៃដុះឡើងវិញ | ១៦៩ | ៦ កន្លែង |
| | ព្រៃគម្ពោធលាយដើមឈើធំមួយៗ | ៨៩១ | ១៨ កន្លែង |
| | ដីកសិកម្មពនេចរ | ៤៣ | ៥ កន្លែង |
| | ស្រូវវស្សា | ១៩៧ | ៣៣ កន្លែង |
| ២ | អន្លង់អភិរក្សទន្លេស្រែពក | ៤ | ៣ កន្លែង ( កន្លែងទី ១អន្លង់កំពង់អក ទី២អន្លង់ពុំរ៉ៃ ទី ៣ អន្លង់បាក់រទេះ) |




**រូបភាពទី៧ :** ព្រំប្រទល់ដែនជំរកសត្វព្រៃលំផាត់

### ១.៣.៣ ស្ថានភាពកសិកម្ម

ប្រជាជនឃុំសិរីមង្គលចំនួន ៨0% ជាអ្នកប្រកបរបរកសិកម្ម ក្នុងនោះ ៧0% ធ្វើស្រែវស្សា និង ១0% ធ្វើកសិកម្មពនេចរ ។ តំបន់នេះជាតំបន់ដែលដីពុំសូវមានជីជាតិទេ ទិន្នផលស្រូវទាបគឺប្រមាណជា១,៨តោន ក្នុងមួយហិកតា ដោយឡែកកសិកម្មពនេចរ គឺធ្វើបានផលល្អប្រសើរតែក្នុងរយៈឆ្នាំទី១តែប៉ុណ្ណោះ ហើយដីនេះត្រូវបាន បោះបង់ចោលរហូតទៅដល់ខួបពី ៥ ដល់ ៨[1] ឆ្នាំទើបអាចវិលមកធ្វើកសិកម្មសារជាថ្មីលើដីនោះបាន ។

**<u>តារាងប្រភេទដំណាំកសិកម្មសំខាន់ៗ និងទិន្នផលទទួលបាន</u>**

| ល.រ | ប្រភេទកសិកម្ម | ផ្ទៃដី ( ហត) | | ផល/ទិន្នផល | |
|---|---|---|---|---|---|
| | | សរុប( ហត) | ដាំបាន ( ហត) | ផលសរុប( តោន) | ទិន្នផល( ត/ហត) |
| ១ | ដំណាំស្រូវវស្សា | ៧៣១.៥១៣ | ៦៨៤ | ១២២៦ | ១.៥ |
| ២ | ស្រូវចំការ | ៤៣.២៣៧ | ១ | 0.៥0 | 0.៥ |
| ២ | ដំណាំពោត | ៤៣.២៣៧ | ២ | ៣ | ១.៥ |



**រូបភាព៣៨ :**ស្រែវស្សា នៅក្នុងឃុំសិរីមង្គល ភូមិស្រែពកតូច

តារាងក្រឡាផ្ទៃតាមផលិតភាពដី ការប្រើប្រាស់ និងផលិតផល

| ល.រ | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមមូលដ្ឋាន) | ផ្ទៃក្រឡា ហិចតា |
|---|---|---|---|
| ១ | **ដីមានផលិតភាពទាប** | **ល្បាយខ្សាច់ - ល្បាយគ្រោះ** | **៤៦២៩០** |
| | ដីកសិកម្មពនេចរ | ពោត ,ដំឡូងមី,អំពៅ,សណ្តែកសៀង, | ១៩ |
| | ព្រៃរបោះ | ខ្លុង,ត្រាច,ត្បែង,កំភ្លា,ក្រវ៉ាន់,ស្នាយ | ៣០៤៤២ |
| | ព្រៃស្រោងស្ងួត | បេង,នាងនួន,កកោះ,ធ្នង់ | ៤៥១០ |
| | ព្រៃស្រោងសើម | គគី,ធ្នឹក,សុក្រម,ស្រឡៅ,ត្រសេក | ២២១ |
| | វាលស្មៅ | ស្មៅ,ព្រិច,បន្ទាសណ្តែកខ្មោច | ២៦ |
| | បឹង | ថ្លុក,ត្រពាំង | ៣ |
| | វាលភក់ | ដីវាលភក់ មិនអាចធ្វើកសិកម្មបាន | ៣៦២ |
| | ព្រៃចំរុះ | កូនឈើច្រើនប្រភេទដុះ | ៣៨៤៦ |
| | ព្រៃដុះតាមមាត់ទឹក អូរ,ស្ទឹង | ត្រាវព្រៃ,ស្នាយ,ស្មោរ | ៤៦៤៧ |
| | ទន្លេ,ស្ទឹង,អូរ | ត្រីឆ្លាំង,ស្លាត,ផ្ទក់,អណ្តែង,ក្រាញ់,ឆ្ពិន,កេះ | ១០៨ |
| | ព្រៃដុះឡើងវិញ | ខ្លុង,ត្រាច,ត្បែង,រការ, | ៩៣២ |
| | ព្រៃគម្លោច,ដើមឈើធំៗ | ឆ្លឹក,ត្រយឹង,ស្តៅ,អង្គ្រង | ៨៩០ |
| | ដីស្រូវវស្សា | សំបុកអង្គ្រង,ក្រសាំងទាប,ផ្កាខ្ញី,រំដួល,សែនពិដោរ,ប្រវឹក | ២៨៤ |
| ២ | **ដីមានផលិតភាពមធ្យម** | **ល្បាយឥដ្ឋ កណ្តេងប្រផេះ និង កណ្តេងខ្មៅ** | **៣៨៥៤** |
| | ដីកសិកម្មពនេចរ | ពោត ,ដំឡូងមី,អំពៅ,សណ្តែកសៀង, | ២៧ |
| | ព្រៃរបោះ | ខ្លុង,ត្រាច,ត្បែង,កំភ្លា,ក្រវ៉ាន់,ស្នាយ | ២៣១៥ |
| | ព្រៃស្រោងស្ងួត | បេង,នាងនួន,កកោះ,ធ្នង់ | ៣៩៨ |
| | ព្រៃស្រោងសើម | គគី,ធ្នឹក,សុក្រម,ស្រឡៅ,ត្រសេក | ៥៩ |
| | វាលស្មៅ | ស្មៅ,ព្រិច,បន្ទាសណ្តែកខ្មោច | ១ |
| | វាលភក់ | ដីវាលភក់ មិនអាចធ្វើកសិកម្មបាន | ១០ |
| | ព្រៃចំរុះ ស្រោងនិង របោះ | កូនឈើច្រើនប្រភេទដុះ | ១៧ |
| | ព្រៃដុះតាមមាត់ទឹក អូរ,ស្ទឹង | ត្រាវព្រៃ,ស្នាយ,ស្មោរ | ៣៧៩ |
| | ទន្លេ,ស្ទឹង,អូរ | ត្រីឆ្លាំង,ស្លាត,ផ្ទក់,អណ្តែង,ក្រាញ់,ឆ្ពិន,កេះ | ១៩០ |
| | ព្រៃដុះឡើងវិញ | ខ្លុង,ត្រាច,ត្បែង,រការ, | ១៦០ |

| | | | |
|---|---|---|---|
| | ដីស្រូវវស្សា | សំបុកអង្រ្កង,ក្រសាំងទាប,ផ្កាខ្ញី,រំដួល,សែនពិដោរ,ប្រវឹក | ២៩៨ |
| ៣ | ដីមានផលិតភាពខ្ពស់ | ល្បាយឥដ្ឋ-កណ្តេងប្រផេះ និងដីក្រហម | ៤០៥៤ |
| | ដីកសិកម្មពនេចរ | ពោត ,ដំឡូងមី,អំពៅ,សណ្តែកសៀង, | ៤០ |
| | ព្រៃរបោះ | ខ្លុង,ត្រាច,ត្បែង,កំភ្លា,ក្រវ៉ាន់,ស្វាយ | ៣៦៣៣ |
| | វាលភក់ | ដីវាលភក់ មិនអាចធ្វើកសិកម្មបាន | ១៣៧ |
| | ព្រៃដុះតាមមាត់ទឹក អូរ,ស្ទឹង | ត្រាវព្រៃ,ស្វាយ,ស្មោរ | ២៦ |
| | ព្រៃដុះឡើងវិញ | ខ្លុង,ត្រាច,ត្បែង,រការ, | ៦៩ |
| | ដីស្រូវវស្សា | សំបុកអង្រ្កង,ក្រសាំងទាប,ផ្កាខ្ញី,រំដួល,សែនពិដោរ,ប្រវឹក | ១៤៩ |
| | | សរុបទាំងអស់ | ៥៤,១៩៨ |

ប្រភព: ទិន្នន័យ GIS ថ្នាក់ជាតិ/សមាសភាគរៀបចំដែនដី/អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម




**រូបភាពទី៩ :** ផែនទីផលិតភាពដី

### ១.៣.៤ ធនធានធម្មជាតិ

#### ១.៣.៤.១ ធនធានព្រៃឈើ

ឃុំសិរីមង្គលសំបូរទៅដោយធនធានធម្មជាតិជាច្រើនដូចជាព្រៃឈើសំខាន់ៗ ដែលមានមុខងារផ្នែក អេកូឡូស៊ីនឹង មុខងារផ្នែកសេដ្ឋកិច្ចយ៉ាងសំខាន់ដែលមានឈើសំណង់ ដូចជាឈើ គគី ស្រឡៅ កកោះ សុក្រម ឈើទាល ផ្ចឿក នាងនួន បេង ឆ្នុង ក្រញូង ដែលប្រភេទឈើទាំងនោះដុះនៅតាមព្រៃស្រោង និងនៅតាមភ្នំ ។ ចំណែកសត្វព្រៃ ដូចជា ឈ្លូស ប្រើស ជ្រូកព្រៃ ខ្ទីង សំបូរនៅតាមព្រៃស្រោង ។ បច្ចុប្បន្ននេះធនធានដែលមានតំលៃទាំងនេះត្រូវបានបាត់បង់បន្តិចម្តងៗ ដោយសារការបំផ្លាញពីក្រុមមនុស្សមួយចំនួនរបស់ក្រុមហ៊ុនខ្សាច់គ្រោះ ព្រៃសម្បទាន ព្រមទាំងការប្រើប្រាស់មិនសមស្របរបស់ប្រជាពលរដ្ឋ ។ បច្ចុប្បន្នប្រជាជននៅក្នុងឃុំ បានកំពុងយកចិត្តទុកដាក់លើការ ការពារធនធានព្រៃឈើ ក៏ដូចជាធនធានធម្មជាតិ សត្វព្រៃ ជីវៈចំរុះឡើងវិញដោយមានបង្កើតគំរោងសហគមន៏ព្រៃឈើ ។ល។

#### ១.៣.៤.២ ធនធានជលផល

ឃុំសិរីមង្គលជាឃុំនៅជាប់ដងទន្លេស្រែពក ដែលកាលពីមុខទន្លេនេះសំបូទៅដោយ មច្ឆាជាតិ និងជីវះចំរុះគ្រប់ប្រភេទ និង នៅបាតទន្លេមានខ្សាច់ដែលជាចំណូលសំរាប់សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋមួយភាគធំដែរ តែមកដល់បច្ចុប្បន្ននេះបើពិនិត្យលើស្ថានភាពនៅក្នុងឃុំសព្វថ្ងៃនៅតាមដងទន្លេស្រែពក ធនធានជលផលមានការថយចុះដូចជាត្រី និង ជីវៈចំរុះ ដែលផលប៉ះពាល់នោះបានបណ្តាលមកពី នៅប្រទេសវៀតណាមគេមានការសាងសង់ទំនប់វារីអគ្គិសនី បានធ្វើអោយទឹកទន្លេមានការឡើងចុះខុសរដូវ ដែលបណ្តាលអោយប៉ះពាល់ដល់ដំណាំ កសិកម្ម និងបន្លែដែលដុះនៅតាមច្រាំងមាត់ទន្លេរបស់ប្រជាពលរដ្ឋមួយភាគធំ ។

បច្ចុប្បន្នប្រពលរដ្ឋនៅក្នុង ឃុំតែងពឹងពាក់ទៅលើប្រភពអូរតូចៗ នៅក្នុងឃុំប៉ុណ្ណោះដែលប្រជាជន អាចរកត្រីក្តាម ខ្ចង នៅតាមដងអូរដោយសារការថយចុះមច្ឆាជាតិ នៅក្នុងទន្លេដែលបណ្តាលមកពីផលប៉ះពាល់វារីអគ្គិសនីនៅប្រទេសវៀតណាម។

## ១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១ ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

ស្ថានភាព

- តម្លៃស្រូវ ១ គីឡូក្រាម = ៨៥0រៀល
- អង្ក ១គីឡូក្រាម = ១.៧00 រៀល

- សាច់ត្រី ១គីឡូក្រាម = ១០,០០០រៀល
- មាន់ ១ តំលៃ ២០,០០០ រៀល
- គ្រឿងផ្ទះ ១ គូប = ៣៥០,០០០ រៀល

### ១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល

- ការទិញចូលស្រូវអង្ករ បានទិញពីអ្នកភូមិ ជិតខាង និងភូមិខ្លួនឯង តែក៏មានមួយចំនួនតូចទិញពីផ្សារ ដែលអង្កនៅលើទីផ្សារត្រូវបាននាំចូលពីទីរួមខេត្តរតនគីរី ។
- ការលក់ចេញនូវ ផលអនុផលព្រៃឈើ ប្រជាជនបាននាំយកទៅលក់នៅទីរួមខេត្ត ជួនកាលក៏មានឈ្មួញមកពីក្រៅមកទិញដែរ ភាគច្រើនតម្រូវការរបស់ឈ្មួញ រួមមានឈើ និងអនុផលព្រៃឈើខ្លះៗដែរ ។
- ចំពោះផលនេសាទវិញសព្វថ្ងៃអ្នករករកស៊ីនៅក្នុងឃុំមានការនាំចេញផលនេសាទទៅទីរួមខេត្តរតនគីរី
- មានការថយចុះដូចច្នេះប្រជាពលរដ្ឋរកបានត្រឹមតែបង្គ្រប់នៅក្នុងជីវភាពគ្រួសារតែប៉ណ្ណោះ ។

### ១.៤.៣ ឱកាស និងឧបសគ្គ

នៅឃុំសិរីមង្គលមាន ធនធានព្រៃឈើ ផ្តល់នូវប្រភពជាចំណីអាហារ អុសដុត សំភារៈប្រើប្រាស់ ប្រភពចំណូលសំរាប់ប្រជាជនមូលដ្ឋាន តែធនធានព្រៃឈើកំពុងតែទទួលការគំរាមកគហែង និងត្រូវបានបាត់បង់ បន្តិចម្តងៗដោយសារការបំផ្លាញពីក្រុមមនុស្សមួយចំនួន ព្រមទាំងការប្រើប្រាស់មិនសមស្របរបស់ប្រជាពលរដ្ឋ កត្តាទាំងនេះបានធ្វើអោយឃុំបាត់បង់នូវចំណូលសេដ្ឋកិច្ចយ៉ាងធំហើយការបាត់បង់នេះនឹងមាន ផលប៉ះពាល់ដល់កូនចៅជំនាន់ក្រោយថែមទៀតផង ។

ចំពោះធនធានជលផល គឺជាធនធានមួយដែលមានសក្តានុពលយ៉ាងខ្ពស់ ក្រៅពីការផ្តល់ជាអាហារ គឺជាប្រភពចំណូលមួយយ៉ាងសំខាន់សំរាប់ប្រជាពលរដ្ឋនៅក្នុងឃុំ ក៏ដូចជាសេដ្ឋកិច្ចជាតិ តែបច្ចុប្បន្នការប្រើប្រាស់ធនធានមានការប៉ះពាល់ គឺធ្វើអោយធនធានទទួលរងនូវគ្រោះថ្នាក់យ៉ាងខ្លាំង ដោយសារការរកផលនេសាទមានលក្ខណៈអនាធិបតេយ្យ ដូចជាការបំពុល ការប្រើម៉ងមានក្រឡាតូច ។ល។ ចំណែកផលប៉ះពាល់ដ៏ធំមួយទៀតគឺមកពីការសាងសង់វារីអគ្គីសនីនៅប្រទេសវៀតណាម ដែលធ្វើអោយទឹកទន្លេមានសកម្មភាពខុសប្រក្រតី ជួនកាលស្រកអស់តែម្តងជួនកាលទឹកអាចឡើង រីឯទឹកមានភាពល្អក់ដែលធ្វើអោយមច្ឆាជាតិ និងជីវះចំរុះមួយភាគធំមិនអាចរស់នៅបាន និងមួយភាគធំប៉ពាល់ដល់ដំណាំកសិផល និងបន្លែធម្មជាតិដែលដុះនៅតាម ដងទន្លេថែមទៀតផង ។

# ជំពូក២

# ការវិភាគតម្រូវការសំរាប់អនាគត

## ២.១ តំបន់រសើប

ដែនជំរកសត្វព្រៃស្ថិតក្នុងឃុំសិរីមង្គល ស្រុកកូនមុំស្ថិតក្រោមការគ្រប់គ្រង ដោយផ្ទាល់របស់ក្រសួងបរិស្ថាន ហើយតំបន់នេះត្រូវបានតែងតាំងដោយព្រះរាជក្រិត ដែលមានទំហំ ៤៣៤១៨ ហិកតា តំបន់ដែនជំរកសត្វព្រៃនៅក្នុងឃុំសិរីមង្គលនេះត្រូវបានដាក់ឈ្មោះថា ដែនជំរកសត្វព្រៃលំផាត់ ដែលអភិរក្សទៅលើសត្វព្រៃគ្រប់ប្រភេទ ដូចជាខ្លា ដំរី គោព្រៃ ខ្លាឃ្មុំ ខ្ទីង ទន្សោង ។ល។ ហើយពួក សត្វព្រៃទាំងនោះជាសម្បត្តិជាតិមានតំលៃ និងមានសារៈសំខាន់សំរាប់ប្រទេសជាតិទាំងមូល និងកំពង់ដើរតួនាទីយ៉ាងសំខាន់បំផុតចំពោះការអភិរក្សធនធានធម្មជាតិជួយរួមចំណែកក្នុងការរក្សាប្រព័ន្ធអេកូឡូស៊ី ស្ថាបនាសេដ្ឋកិច្ច វប្បធម៌និងវិស័យអប់រំ ។ យើងបានដឹងរួចមកហើយថានៅ លើពិភពលោកយើងនេះមានសត្វព្រៃជាច្រើនប្រភេទដែលវាមានការរស់នៅទៅ តាមបែបផែននៃលក្ខណះជីវសាស្ត្រតាមក្រុមប្រភេទ និង គ្រួសារនិមួយៗ ប្រភេទសត្វព្រៃនីមួយៗសុទ្ធតែមានលក្ខណៈពិសេសរៀងៗខ្លួនមានប្រភេទខ្លះងាយ ស្រួលក្នុងការអភិរក្ស និងប្រភេទខ្លះទៀតមានការលំបាកក្នុងការការពារអោយបានគង់វង្ស ពីព្រោះវាជាប្រភេទ ដែលជាតំរូវការចាំបាច់របស់មនុស្ស និងងាយទទួលរងគ្រោះថ្នាក់ព្រមទាំងធ្វើការវិវត្តន៏នូវចំនួនរបស់វា មានលក្ខណៈ យឺតបំផុត។

ដោយឡែកឃុំសិរីមង្គលក៏មានទន្លេហូរកាត់ នៅចំកណ្តាលដែលកាលពីមុនទន្លេស្រែពកនៅក្នុងឃុំគឺសំបូរទៅដោយពពួកមឆ្លាជាតិយ៉ាងច្រើនដោយទន្លេនៅក្នុងឃុំ មានអន្លង់ធំ៧៣ ដែលអន្លុងទាំង ៣ នោះមច្ឆាជាតិចូលចិត្តទៅរស់នៅទីនោះណាស់នៅពេលខែទឹកស្រកមកដល់ បច្ចុប្បនេះមច្ឆាជាតិនៅក្នុងអន្លុង ស្ទើរបាត់បង់ផុតពូជស្ទើរតែអស់ទាំងស្រុង ដោយការនេសាទខុសច្បាប់ ដូចជាប្រើឧបករណ៏ឆក់ និងបំពុលដែលធ្វើអោយបាត់ចំណូលយ៉ាងច្រើនចំពោះប្រជាជនដែលមានមុខរបរនេសាទ ។

## ២.២ ការប្រឈម/ឧបស័គ្គ

បច្ចុប្បន្នការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំសិរីមង្គលបានជួបប្រទះនូវបញ្ហាមួយចំនួន សំរាប់ការអភិវឌ្ឍន៏ក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រុមប្រឹក្សាឃុំក៏ដូចជាប្រជាជនបានលើកយកមកបង្ហាញរួមមានៈ បញ្ហាសេដ្ឋកិច្ច និងសង្គមកិច្ច ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លី និង ធនធានធម្មជាតិ ។ ការគំរាមកំហែងចម្បងចំពោះស្ថានភាពសត្វព្រៃនៅក្នុងដែនជំរកសត្វ គឺការកាប់ឈើខុសច្បាប់ និងការកាប់រានដី សំរាប់គោលបំណងជាកម្មសិទ្ធិ ដែលបង្កអោយមានការកាប់ បំផ្លាញនិងបាត់បង់ទីជំរកក៏ដូចជាការរំខានទៀតផង។ ការបរបាញ់ខុសច្បាប់ដើម្បីផ្តល់ម្ហូបអាហារសំរាប់ប្រើប្រាស់ក្នុងមូលដ្ឋាន និងម្តងម្កាលលក់នៅលើទីផ្សារនានា និងបានបន្ថែមបញ្ហាកាន់តែធ្ងន់ធ្ងរថែមទៀត។ ម៉្យាងទៀត ឃុំសិរីមង្គលជា ឃុំមួយស្ថិតនៅជិតមាត់ទន្លេស្រែពក ហើយភាគច្រើនជាដីរបស់ឃុំគ្របដណ្តប់ ទៅព្រៃឈើ

មួយភាគធំ ដោយយោងលើ ផែនទីគំរបព្រៃឈើឆ្នាំ ២០០២បានអោយដឹងថាផ្ទៃដីរបស់ឃុំមានចំនួន ៩៤៥៤៨,៤០៨ ហិកតា ចែកចេញជា :

-ព្រៃស្រោងចំនួន ១២៧៤,៩២៥ ហិកតា

-ព្រៃពាក់កណ្ដាលស្រោងចំនួន ៣៥១៦,៦៨៩ ហិកតា

-ព្រៃល្បោះ ចំនួន ៤១៦២៤,៨៩ ហិកតា

-ដីមិនមែនព្រៃ ចំនួន ៨១៣១,៩០៨ ហិកតា

ដោយសារផ្ទៃដីឃុំ មួយភាគធំគ្របដណ្ដប់ទៅដោយព្រៃឈើ ដែលមានតំលៃខ្លាំងណាស់ក្នុងការផ្ដល់ជាឈើសំណង់ និងផលអនុផលព្រៃឈើជាច្រើនទៀតដែលអាចផ្ដល់តំរូវការប្រើប្រាស់របស់ប្រជាពលរដ្ឋជាពិសេសអ្នករស់នៅជនបទព្រៃភ្នំ និងជួយទ្រទ្រង់និយ័ត្តភាពប្រព័ន្ធជលសាស្ត្រ និងធនធានជីវចំរុះ។ ដោយសារធនធានមានក៏រិតកំណត់ យើងបានប្រឈមនិងការលំបាកជាច្រើនក្នុងការការពារ និងគ្រប់គ្រងដោយនិរន្តភាពនូវធនធានព្រៃឈើ របស់យើង។ ដោយមានជនខិលខូចមួយចំនួនត្រូវបានចូលបំផ្លិចបំផ្លាញដូចជា : លួចអារឈើបែបអនាធិបតេយ្យ នៅតំបន់ព្រៃឈើជ្រៅៗដូចជាចំនុចស្ពង់ ស្ថិតនៅក្នុងភូមិនាងដី និងមានការចាប់យកដីព្រៃកាប់រានយកមកធ្វើ ជាកម្មសិទ្ធិផ្ទាល់ខ្លួនជាដើម ។

សព្វថ្ងៃបើយើងក្រឡេកទៅមើលផ្នែកកសិកម្ម ឃុំមានផ្ទៃដីធំទូលាយ តែទិន្នផលដំណាំដែលបានមកពីរបរកសិកម្មរបស់ប្រជាពលរដ្ឋ ទទួលបាននៅទាបនៅឡើយ ដូចជាផលស្រូវទទួលបានជាមធ្យមពី១,៨ ដល់ ២ តោន ក្នុងមួយ ហិចតា សំរាប់ផ្គត់ផ្គង់ តែការហូបចុក និង ដំណាំរួមផ្សំ បន្លែ ផ្លែឈើ ពុំអាចផ្គត់ផ្គង់តំរូវការហូបចុកគ្រប់គ្រាន់ ទាមទារមានការនាំចូល ពីទីរួមខេត្ត បច្ចុប្បន្ននេះ ឃុំពុំទាន់បានទាញយកផល ប្រយោជន៏ពីសក្ដានុពលលើវិស័យនេះបានសមស្របនៅឡើយ ដោយមានប្រជាពលរដ្ឋចំនួនប្រមាណ ៦៥-៧៥% រកចំណូលបានទាប គឺជាអ្នកដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ។ ហើយការប្រើប្រាស់ដីស្រែ និងដីចំការ កន្លងមកប្រជាជននៅក្នុងឃុំពួកគាត់មិនបានគិតពីផលប៉ះពាល់ទៅលើដីនៅឡើយទាំងនេះគឺអាស្រ័យលើការប្រើប្រាស់ដែលពុំបានគិតពីលក្ខណៈបច្ចេកទេសកសិកម្ម ដែលជាហេតុបណ្ដាលអោយដី ទទួលរងនូវគ្រោះថ្នាក់នៃការបាត់បង់ជីជាតិ ដែលមូលហេតុនេះរួមមានជាអាទិ៍ មកពីការធ្វើកសិកម្មមិនមានបច្ចេកទេសគ្រប់គ្រាន់ ការដាំដំណាំដដែលៗលើផ្ទៃដីតែមួយ ការប្រើប្រាស់ជីគីមីមិនត្រឹមត្រូវ ដែលធ្វើឱ្យដីខ្សោះជីជាតិ និងខូចរចនាសម្ព័ន្ធដី ក៏ដូចជាសារធាតុជីវចំរុះក្នុងដី ។

ម៉្យាងវិញទៀតឃុំតែងតែជួបនូវបញ្ហា គ្រោះទឹកជំនន់ និងរាំងស្ងួតដែលធ្វើអោយលិចលង់ និងស្ងួតខូចស្រូវស្រែចំការ ហើយមានការខូចខាតលើហេដ្ឋារចនាសម្ពន័ ដូចជាផ្លូវក្នុងការធ្វើដំណើរ ហើយមួយទៀតកុមារភាគច្រើនមិនបានចូលរៀនក្រុមជនងាយរងគ្រោះដូចជាជនពិការ ស្ត្រីមេម៉ាយ កុមារកំព្រា និង មនុស្សចាស់ជរា ជាពិសេសបញ្ហាសុខភាព ក៏ជាអាទិភាពមួយដ៏ចំបងរបស់ឃុំ មូលហេតុដោយសារតែ មណ្ឌលសុខភាពនៅឆ្ងាយ ហើយសេវាដឹកជញ្ជូនអ្នកជំងឺនៅពុំទាន់បានដោះស្រាយនៅឡើយ ។ ចំពោះបញ្ហាកើតឡើងដែលគួរអោយកត់សំគាល់ នៅតាមដងអូរ និង

បឹងគឺមានការឆក់ និងប្រើថ្នាំបំពុលដែលធ្វើអោយមានការប៉ះពាល់លើបរិស្ថាន និងមច្ឆាជាតិ ជាពិសេសដងទន្លេស្រែពក ដែលជាកន្លែងការពារសំរាប់សហគមន៍ឃុំ ដែលបច្ចុប្បន្នឃើញថាមច្ឆាជាតិ មានការថយចុះ យ៉ាងខ្លាំង ។ តាមការវិភាគ បញ្ហានៅក្នុងឃុំឃើញថា មានការកើនឡើង អ្នកចំណូលមករស់នៅក្នុងឃុំ ច្រើនគួរអោយ កត់សំគាល់ កត្តានេះធ្វើ អោយមានការបាត់បង់ព្រៃឈើ ក៏ដូចជាសត្វព្រៃផងដែរមូលហេតុដោយសារការកាប់រានដើម្បីបានដីមកធ្វើ ជាកម្មសិទ្ធិ និងសំរាប់លក់ ។ ការប្រឈមទាំងអស់ខាងលើនេះ នឹងនាំមកនូវ តម្រូវការដីកាន់ តែច្រើនដែលក្នុងនោះ មានទាំងដី សំរាប់បង្កបង្កើនផល និងដីសំរាប់តែកម្មសិទ្ធិហើយជាលទ្ធផលរួមគឺការបាត់បង់ព្រៃលិចទឹកវាលស្មៅ និងបឹងបួរធម្មជាតិ ហើយនាំទៅដល់ការបាត់បង់ធនធានព្រៃលិចទឹក ធនធានជលផល ជីវៈចំរុះ ហើយបច្ច័យចុងក្រោយគឺធនធានដីកាន់តែ រេចរិលជាបន្តបន្ទាប់ ។

## ២.៣ តម្រូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំសេរីមង្គល

តារាងក្របខ័ណ្ឌនៃការអភិវឌ្ឍន៏ ដោយធ្វើយ៉ាងណាសង្ខេបចេញជាចក្ខុវិស័យរួម/គោលបំណងរយៈ ពេលវែង ១០-១៥ឆ្នាំ ដែលគ្របដណ្តប់គ្រប់វិយទាំងអស់ហើយបំបែកជាគោលបំណង/គោលដៅរយៈពេលមធ្យមទៅតាមវិស័យ និងផ្នែកនីមួយៗ ។ ដើម្បីទ្រទ្រង់បាននូវយុទ្ធសាស្ត្ររួម សំដៅធ្វើអោយការអនុវត្តន៏ សំរេចបានដល់គោលដៅនៃ ចក្ខុវិស័យដែលបាន កសាងឡើងខាងលើចាំបាច់ត្រូវកសាងយុទ្ធសាស្ត្រលើវិស័យសំខាន់ៗ ដែលពាក់ពន្ធ័មួយចំនួនដល់ ការអភិវឌ្ឍន៏ឃុំ ។ យុទ្ធសាស្ត្រតាមវិស័យសំខាន់ៗ ទាំងនោះ ក្រុមប្រឹក្សាឃុំ និងគជថ និងប្រជាពលរដ្ឋទាំងអស់ នៅក្នុង ឃុំបានជ្រើសរើសយកគោលដៅដូចខាងក្រោម :

**គោលដៅអភិវឌ្ឍន៏ទី១ ផ្នែកសេដ្ឋកិច្ចៈ**

នៅឆ្នាំ ២០០៩ ដល់ ឆ្នាំ ២០២២ ប្រព័ន្ធគមនាគមន៏នៅឃុំសេរីមង្គលត្រូវបានពង្រីកដល់គ្រប់ភូមិ និងមាន ទិន្នផលស្រូវសំរាប់ហូប និង លក់បង្កើនប្រាក់ចំណូល ផ្គត់ផ្គង់គ្រួសារគ្រប់គ្រាន់ ដល់ប្រជាពលរដ្ឋក្មេង ចាស់ ប្រុស ស្រី ការធ្វើដំណើរបានស្រួលដោយមានការសាងសង់ស្ពានឈើ លូបន្ថែម មានសុវត្ថិភាព ចំណេញពេលវេលា នឹងមានជីវភាព រស់នៅបានល្អប្រសើរ ដល់គ្រួសារចំនួន ៥០ភាគរយ នៃគ្រួសារសរុបក្នុងឃុំទាំងមូល ។

១.១. យុទ្ធសាស្ត្រអភិវឌ្ឍន៏ៈ បង្កើនការចិញ្ចឹមសត្វ

១.២. យុទ្ធសាស្ត្រអភិវឌ្ឍន៏

១.៣. ជម្រុញឱ្យវិស័យកសិកម្មឱ្យរីកចំរើន

**គោលដៅអភិវឌ្ឍន៍ទី២ ផ្នែកសង្គមកិច្ច :**

នៅឆ្នាំ ២០០៩ ដល់ឆ្នាំ ២០២២ ប្រជាពលរដ្ឋទាំងពីរភេទ នៅឃុំសេរីមង្គល មានសេវាសុខភាព សំរាប់ ផ្គត់ផ្គង់កាន់តែល្អប្រសើរ ដោយមានការសាងសង់បុស្តិ៍សុខភាព មានទឹកស្អាតប្រើប្រាស់គ្រប់គ្រួសារ ដោយស្ត្រី និងកុមារមានកន្លែងព្យាបាលជំងឺ និង ប្រឹក្សាជំងឺទូទៅ នៅនឹងមូលដ្ឋានភូមិឃុំផ្ទាល់ខ្លួន ។

២.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍ : បង្កើនឱ្យមានសុវត្ថិភាព ដល់ស្ត្រី

២.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍ : ជម្រុញកុមារឱ្យចូលរៀន

២.៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍ : បង្កើនការការពារជំងឺគ្រុនឈាម និង គ្រុនចាញ់

២.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍ :បង្កើនការប្រើប្រាស់ទឹកស្អាត និង ថែទាំសុខភាព

**គោលដៅអភិវឌ្ឍន៍ទី ៣ ផ្នែកធនធានធម្មជាតិ និង បរិស្ថានៈ**

នៅឆ្នាំ ២០០៩ ដល់ ឆ្នាំ ២០២២ ក្នុងសហគមន៍មានការយល់ដឹងអំពីច្បាប់គ្រប់គ្រង ព្រៃឈើ សត្វព្រៃ ត្រី ព្រមទាំងការចូលរួមថែរក្សា និង ប្រើប្រាស់ធនធានធម្មជាតិ មានប្រសិទ្ធភាពខ្ពស់ និងមាននិរន្តភាព សំរាប់កូនចៅទៅថ្ងៃអនាគត បានល្អប្រសើរ ដោយមានការចូលរួមសហការ គ្រប់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋមូលដ្ឋានទាំងពីរភេទ ។

៣.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍ : បង្កើនការថែរក្សាព្រៃឈើ និង ធនធានជលផល

**គោលដៅអភិវឌ្ឍន៍ទី ៤ ផ្នែកសេវាកម្មរដ្ឋបាល និង សន្តិសុខ**

នៅឆ្នាំ ២០០៩ ដល់ ឆ្នាំ ២០២២ ប្រជាពលរដ្ឋនៅឃុំសេរីមង្គលទាំងមូលមានការយល់ដឹង អំពីសិទ្ធិនៃការគ្រប់គ្រងប្រើប្រាស់ដីធ្លីឱ្យមាន និរន្តភាព និងមានការគិតគូរដល់កូនចៅជំនាន់ក្រោយ ដែលរស់នៅពឹងផ្អែកលើការធ្វើស្រែ ចំការ និងបង្កើនការទទួលខុសត្រូវ គោរពរាប់អានគ្នា និងទទួលបានសុវត្ថិភាព ក្នុងសហគមន៍។

៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍ : រៀបចំដីបំរុង សំរាប់ស្រែចំការ

៤.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍ : បង្កើនសមត្ថភាពអនុវត្តន៍ ការងារ នៅមូលដ្ឋាន

**គោលដៅអភិវឌ្ឍន៍ទី៥ ផ្នែក យេនឌ័រ :**

នៅឆ្នាំ ២០០៩ ដល់ ២០២២ ស្ត្រីមានការទទួលខុសត្រូវដូចបុរស រាល់ការចូលរួមនៅមូលដ្ឋាន និងមានជំនាញក្នុងការប្រកបរបរចិញ្ចឹមជីវិត ដោយមិនពឹងផ្អែកលើការរុករកអនុផលព្រៃឈើទាំងស្រុង ព្រមទាំង ការបង្កើន និង ផ្តល់ឱកាសឱ្យស្ត្រីបានចូលរួម និងសំរេចចិត្តក្នុងការលើកស្ទួយការងារអភិវឌ្ឍន៍ ។

**៥.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍ :** ទប់ស្កាត់ការជួញដូរស្ត្រី និង កុមារ និង ការកាត់បន្ថយទំនាស់ក្នុងគ្រួសារ

## ២.៤ តម្រូវការដីសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

#### ២.៤.១.១ អត្រាកំណើន

ស្ថានភាពអត្រាកំណើននៃ ប្រជាពលរដ្ឋនៅក្នុងឃុំសិរីមង្គលបើពិនិត្យនៅក្នុងឆ្នាំ ២០០៥ មានចំនួនគ្រួសារ ៣១២ គ្រួសារដែលស្មើនឹងប្រជាពលរដ្ឋចំនួន១២៩៦នាក់ បើយើងធ្វើការប្រៀបធៀបនៅឆ្នាំ ២០០៦ មានការកើនឡើងតែ ៦ គ្រួសារស្មើ ៨៧នាក់ ដូចនេះ ចំពោះចំនួនមនុស្សមានចំនួនច្រើនជាងនៃចំនួនគ្រួសារ ។ តែចំនួនគ្រួសារក្នុងឆ្នាំ ២០០៦នេះមានចំនួន ៣៣៩គ្រួសារ ស្មើនិង ២២៣០នាក់។ តែបើយើង ពិនិត្យទៅលើឆ្នាំ ២០០៦ ធៀបទៅនឹងឆ្នាំ ២០០៧ ឃើញថាមានការកើនឡើងនៃចំនួនគ្រួសារ រហូតដល់២៩គ្រួសារស្មើនឹងចំនួនគ្រួសារ ២៣២នាក់ដែលចំនួន

គ្រួសារ ឆ្នាំ ២០០៧ នេះមានចំនួន ៣៨៤ គ្រួសារ ស្មើនិង ២៤១០ នាក់ ចំណែកឯ ឆ្នាំ ២០០៨ ឃើញថាមានការកើនឡើងចំនួន តែ ៣នាក់ តែចំនួនប្រជាជនមានការថយចុះ ៨០៩ នាក់

តាមការសាកសួរព័តិមានពីក្រុមប្រឹក្សាឃុំ និង អ្នកចូលរួមនៅក្នុងឃុំ ដែលបណ្តាលមកពីការឡើងចុះនៃចំនួនប្រជាពលរដ្ឋនៅក្នុងឃុំ គឺបណ្តាលមកពី ការហូរចូល និងធ្វើចំណាកស្រុកចេញទៅរកមុខរបរនៅក្រៅមូលដ្ឋាន តែចំនួនគ្រួសារ និងចំនួនប្រជាពលរដ្ឋតាមបណ្តាឆ្នាំមានការ កើនឡើងជាលំដាប់ ហើយចំនួនកុមារក៏មានការកើនឡើងដែរ កត្តានេះហើយដែលបណ្តាលអោយមានការកង្វះខាតនៅទីកន្លែងសិក្សា និងមានការខ្វះខាតដី ក្នុងការ ពង្រីកដីនៅក្នុងវិស័យកសិកម្មដែរ ដូច្នេះយើងក៏ត្រូវកំណត់នូវសក្តានុពលមួយចំនួនដូចជាលទ្ធភាព នៃកាពង្រីកអាគារសិក្សាការង្កើនមុខរបរការធ្វើស្រែបង្កើនរដូវ ការបង្កើននូវទិន្នផលកសិកម្មការរៀបចំប្រព័ន្ធស្រោចស្រព្វការអភិរក្ស នូវធនធានធម្មជាតិ និងការកំណត់នៃការប្រើប្រាស់ធនធានអោយបានសមស្របទើបអាចធានាបាននូវអត្រាកំណើន ។

តារាង ការគណនាអត្រាកំណើនមធ្យម

| **ចំនួនគ្រួសារ/ប្រជាជន** | **២០០៥** | **២០០៦** | **២០០៧** | **២០០៨** | **កំណើនមធ្យម** | **កំណើន/ឆ្នាំ** |
|---|---|---|---|---|---|---|
| ចំនួនគ្រួសារសរុប | ៣១២ | ៣៤១ | ៣៨៤ | ៣៨៧ | - | - |
| អត្រាកំណើនគ្រួសារ | - | ៩% | ១% | ១% | ៤% | ១៤គ្រួសារ |
| ចំនួនប្រជាជនសរុប | ១២៩៦ | ១៥២៨ | ២៤១០ | ១៦០១ | - | - |
| អត្រាកំណើនប្រជាជន | - | ១៨% | ៥៨% | -៣៤% | ១៤% | ២២៤នាក់ |

ប្រភព: ឯកសារ ស្តីពីស្ថានភាពឃុំ ឆ្នាំ ២០០៨

នៅក្នុងអត្រានៃការប្រែប្រួលចំនួនគ្រួសាររបស់ប្រជាពលរដ្ឋ នៅក្នុងអំឡុងឆ្នាំ ២០០៥-២០០៦ ឃើញថាមានការកើនឡើង តែ ៩% ប៉ុន្តែឆ្នាំ ២០០៦-២០០៧ អត្រាកើនឡើងនៃគ្រួសារមានចំនួនតែ ១%ស្មើនឹងអត្រាប្រជាជនចំនួន ៥៨% ប៉ុណ្ណោះ និងឆ្នាំ២០០៧-២០០៨ អត្រាគ្រួសារ ១% ស្មើនឹងអត្រាប្រជាជនមាន ការថយចុះ ៣៤ %ទៅវិញ ដូចនេះបើតាមគណនា អត្រាកំណើនចំនួនគ្រួសារ ពីឆ្នាំ ២០០៥-២០០៨ ឃើញថាអត្រាកំណើនមាន ៤% ស្មើនិង ១៤គ្រួសារក្នុងមួយឆ្នាំ ។ផ្អែកតាមទិន្នន័យព័តិមាននៃផែនការអភិវឌ្ឍន៍ឃុំ និងតាមរយះការគណនារកអត្រាកំណើនរបស់ប្រជាពលរដ្ឋ ឃើញថា ចំនួនប្រជាជនពីមួយឆ្នាំទៅមួយឆ្នាំមានការប្រែប្រួលកើនឡើងនិងឆ្នាំខ្លះមានការថយចុះ កត្តានេះគឺ អាស្រ័យ ដោយមូលហេតុដូចករណីខាងលើ ប៉ុន្តែទោះជាយ៉ាងនោះក៏ដោយក៏អត្រាកំណើនជាមធ្យម ៤% ដែលក្នុង នោះមានការ កើនឡើងក្នុង ១ ឆ្នាំ ២២៤នាក់ ។

### ២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ

ការធ្វើចំណោលប្រជាសាស្ត្រគឺសំរាប់ការទស្សន៍ទាយកំណើនប្រជាជនជាចំណុចដ៏សំខាន់ណាស់ សំរាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឃុំសិរីមង្គល ។ ការដឹងជាមុននូវចំនួនដង់ស៊ីតេប្រជាជន គឺជាមធ្យោបាយដ៏សំខាន់មួយ

ដើម្បីធ្វើការកំណត់ជាមុននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗរបស់ឃុំនាពេលអនាគត ។ ដូចនេះការលើកយកចំនួន ប្រជាជនក្នុងឆ្នាំ២០០៨ មកធ្វើការប្រៀបធៀប និងទស្សន៍ទាយពីកំណើនប្រជាជនទៅថ្ងៃអនាគត( ឆ្នាំ២០០៨ និង២០២២) គឺជាយុទ្ធសាស្ត្រមួយសំរាប់ប្រើប្រាស់ និង អនុវត្តផែនការអភិវឌ្ឍន៍ឃុំ ក្នុងរយៈពេល ១៥ ឆ្នាំ ។

តារាងការធ្វើចំណោលប្រជាសាស្ត្រ

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ ២០១២ | | ឆ្នាំ ២០១៧ | | ឆ្នាំ ២០២២ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| អាយុក្រោម០៥ឆ្នាំ | ២៤០ | ១៣៩ | ៣៤៨ | ២០១ | ៤៥៦ | ២៦៣ | |
| អាយុ ០៥ឆ្នាំ | ១៦២ | ៨៦ | ២៣៥ | ១២៤ | ៣១១ | ១៦៣ | |
| អាយុពី ៦-១១ឆ្នាំ | ៣២១ | ១៧៦ | ៤៦៥ | ២៥៥ | ៦១០ | ៣៣៤ | |
| អាយុពី ១២-១៤ឆ្នាំ | ១៩២ | ៩២ | ២៧៨ | ១៣៣ | ៣៦៤ | ១៧៥ | |
| អាយុពី ១៥-១៧ឆ្នាំ | ១៩៣ | ១០៨ | ២៨០ | ១៥៦ | ៣៦៧ | ២០៤ | |
| អាយុពី ១៨-២៤ឆ្នាំ | ៣៣៥ | ១៨៦ | ៤៨៦ | ២៦៩ | ៦៣៦ | ៣៥២ | |
| អាយុពី ២៥-៦០ឆ្នាំ | ៩០៨ | ៥០១ | ១៣១៥ | ៧២៥ | ១៧២៣ | ៩៥០ | |
| អាយុពី៦១ឆ្នាំឡើងទៅ | ១៤៣ | ៧៥ | ២០៨ | ១០៨ | ២៧២ | ១៤២ | |
| **ចំនួនប្រជាជនសរុប** | **២៤៩៧** | **១៣៦២** | **៣៦១៧** | **១៩៧២** | **៤៧៣៦** | **២៥៨៣** | |
| **ចំនួនគ្រួសារសរុប** | **៥៤១** | | **៧៨៤** | | **១០២៧** | | |

អត្រាកំណើនប្រជាពលរដ្ឋនៅក្នុងឃុំសិរីមង្គល បើពិនិត្យទៅលើកំណើនក្នុងរយៈពេល ៥ ឆ្នាំសំរាប់រយះពេល ១៥ ឆ្នាំខាងមុខ ឃើញថាអត្រាកំណើនប្រជាពលរដ្ឋជាមធ្យម ៤%ក្នុងនោះស្មើរនិង ១៤គ្រួសារក្នុងមួយឆ្នាំ ហើយនិង ១៤% ស្មើរនិង ២២៤ នាក់ក្នុង១ឆ្នាំ នោះបើពិនិត្យទៅលើបរិមាណផ្ទៃដីដែលអាចប្រើប្រាស់បាននៅមានកំរិត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏យើងត្រូវចាប់អារម្មណ៏ដល់ការអភិវឌ្ឍន៍ដែរ ព្រោះអត្រាកំណើនរបស់ប្រជាពលរដ្ឋនៅក្នុងឃុំសិរីមង្គល គឺវាពាក់ព័ន្ធទៅលើការអភិវឌ្ឍន៍ធនធានដែលមានក្នុងឃុំពិសេសបរិមាណដី ដែលអាចបង្កើននូវផល ដើម្បីធានាស្បៀង ក្នុងតំបន់ ។

### ២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន

ចំពោះដីលំនៅដ្ឋានគឺសំដៅទៅដល់ ដីដែលប្រើប្រាស់សំរាប់សង់ផ្ទះ និងសំរាប់ដាំដំណាំជាគ្រួសារនៅជុំវិញ (លំអិតសូមមើលឧបសម្ព័ន្ធ១)សំរាប់ឆ្នាំគោល ២០០៨ មានទំហំ ៣៦ហិកតា សំរាប់ប្រជាជន ប្រមាណជា ១៦០០ នាក់ ស្មើរនឹង ៣៤៧ គ្រួសារ ដូច្នេះទំហំដីសំរាប់មួយគ្រួសារគិតជាមធ្យមគឺមាន ០,០២៣ ហិកតា គឺ តិចជាងដី

សំរាប់សង់ លំនៅដ្ឋានដែលមាន ១២០០-៣៦០០ម[២] (មាត្រាទី១៥ ជំពូក៥នៃអនុក្រិត្យ ស្តីពីសម្បទាន ដីសង្គមកិច្ច) ដោយសារឃុំសិរីមង្គលដីពុំមានវិសាលភាពគ្រប់គ្រាន់ ដូច្នេះក្នុងការប៉ាន់ប្រមាណដី សំរាប់សង់លំនៅដ្ឋានត្រូវកំណត់យក ១២០០ម[២] ។ ដើម្បីធានាអោយប្រជាជនដែលខ្វះដី មានដីមិនគ្រប់គ្រាន់ និងប្រជាជនដែលកើនឡើងនៅឆ្នាំ ២០២២ មានដីលំនៅដ្ឋានសមរម្យ យើងត្រូវពិចារណាដូចខាងក្រោមៈ

តម្រូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

| | | |
|---|---|---|
| - ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីលំនៅដ្ឋាន | ០៩ គ្រួ. x 0,១២ = ១,០៨ ហត. | |
| - កំណើនគ្រួសារ ពីឆ្នាំ ២០០៨-២០២២ | ៦៨០ គ្រួ. x 0,១២ = ៨១,៦ ហត. | |
| | សរុប | **៨២.៦៨ ហត.** |

## ២.៤.៣ តម្រូវការដីកសិកម្ម

តម្រូវការដីកសិកម្មគឺរួមមានដីសំរាប់ ស្រែវស្សា និងចំការដំណាំផ្លាស់វេន (លំអិតសូមមើលឧបសម្ព័ន្ធ១) សំរាប់ឆ្នាំគោល ២០០៨ មានទំហំ ៨៤៨.៤៨ ហិកតា សំរាប់ប្រជាជនសរុប ២៥២៦ នាក់ ស្មើនិង ៤៦៤ គ្រួសារ ដូច្នេះទំហំដីជាមធ្យមសំរាប់មួយគ្រួសារមាន ១.៨២ ហិកតា។ ដូចនេះប្រជាជនដែលអាចមានដីជាមធ្យមទំហំ ២ ហិកតា[២] ក្នុង១គ្រួសារ ដែលជាទំហំដីសមស្របសំរាប់ប្រជាជនមួយគ្រួសារ។

តម្រូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

| | | | |
|---|---|---|---|
| - គ្រួសារដែលបច្ចុប្បន្នគ្មានដីស្រែផ្ទាល់ខ្លួន | ២៦ គ្រួ. x ២ | = | ៥២ ហត. |
| - ចំនួនគ្រួសារដែលបច្ចុប្បន្នមានដីស្រែតិចជាង ១ ហិកតា | ៣០ គ្រួ. x ១,៥០ | = | ៤៥ ហត. |
| - កំណើនគ្រួសារ ២០២២ | ៦៨០ គ្រួ. x ២ | = | ១៣៦០ ហត. |
| | សរុប | | **១៤៥៧ ហត.** |

## ២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ

ឃុំសិរីមង្គលជាឃុំ សំបូរដោយព្រៃឈើធនធានធម្មជាតិ មានបឹង អូរ និងដីមានជីវជាតិដូចនេះដីដែលបាន កំណត់ នៅក្នុងតំបន់រសើប គឺមានដីដែលស្នើសុំបង្កើតសហគមន៍ព្រៃឈើ ៣កន្លែង តំបន់អភិរក្សជំរកសត្វព្រៃលំផាត់ ១កន្លែង តំបន់អន្លង់ ឡូនេសាទ ៣ កន្លែងនៅក្នុងទន្លេស្រែពក ។

ចំណែកដីផ្សេងៗទៀតដែលមិន បានកំណត់ទៅក្នុងប្រភេទ នៃការប្រើប្រាស់ដីគឺត្រូវតែទុកអោយនៅជាដីព្រៃ និងវាលស្មៅ ដីដែលដែលជាដីរបស់រដ្ឋ ដើម្បីធានានូវតម្រូវការដី សំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដែលមានការចាប់អារម្មណ៏ទៅលើការការពារ និងទប់ស្កាត់អោយបាន ជាដាច់ខាតនូវការលួចកាប់រំលោភយកដី ពីសំណាក់ជនខិលខូច និងចាត់វិធានការអោយបានខ្លាំងក្លាបំផុតសំរាប់ ជនទាំងនោះ ។

## ២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធសង្គម

ជារួមហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងរូបភាពតូចតាច គឺត្រូវបានបញ្ចូលទៅក្នុងដីលំនៅដ្ឋាន ឬដីទីប្រជុំជន ដោយមិនបានញែកចេញដោយឡែកនោះទេ (ក្នុងនោះដីកប់ខ្មោច វត្ត អាស្រម ក៏គិតគូរក្នុងនេះដែរ) តែក្នុងនោះ ក៏មានការគិតគូរជារួម លើកលែងតែហេដ្ឋារចនាសម្ព័ន្ធ សង្គមដែលមានទ្រង់ទ្រាយធំ ទើបមានការគិតគូរដោយឡែក។ និយាយរួមដីសំរាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានកំណត់ជារួមជាមួយនឹងដីត្រៀមបំរុង សំរាប់ពង្រីកទីប្រជុំជន។

តាមការប៉ាន់ប្រមាណជាសរុប ដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គមគឺមានតម្រូវការបន្ថែមចំនួន ១៣ ហិកតា រួមមានដីសំរាប់សាងសង់វត្ត ដីសំរាប់សាងសង់ប៉ុស្តិ៍រដ្ឋបាលឃុំ ដីសំរាប់សាងសង់អណ្តូងទឹកស្អាត ដីសំរាប់សាងសង់ប៉ុស្តិ៍សុខភាពភូមិ ចំណែកដីធ្វើផ្លូវ ទំនប់តូចៗ គឺមិនមានការគិតជាផ្ទៃដីទេ តែមានប្រវែងហើយនឹងបង្ហាញក្នុងផែនទីដោយឡែក ។

<u>តារាងផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មទូទៅ</u>

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | 0 | ១សាលា ០៣បន្ទប់ | ១សាលា ០៣បន្ទប់ |
| សាលាបឋមសិក្សា | ០៣ សាលា ៩បន្ទប់ | ០៥សាលា ១៩បន្ទប់ | ០២ សាលា ១០បន្ទប់ |
| សាលាអនុវិទ្យាល័យ | 0 | ១សាលា ០៦ បន្ទប់ | ១សាលា ០៦ បន្ទប់ |
| សាលាវិទ្យាល័យ | 0 | ០២សាលា ០៨បន្ទប់ | ០២សាលា ០៨បន្ទប់ |
| ប៉ុស្តិ៍សុខភាព | 0 | ០១អាគារ | ០១ អាគារ |
| អណ្តូងទឹកស្អាត | 0 | ២០ | ២០ |
| ជីកស្រះ | 0 | ០៩ | ០៩ |
| ស្នាក់ការបរិស្ថាន | 0 | ០១ | ០១ |

ប្រភព: ការប្រជុំនៅថ្នាក់ឃុំ

### ២.៤.៥.១ តម្រូវការសាលារៀន

ដីសំរាប់សាងសង់សាលារៀនមានការកំណត់បានច្បាស់លាស់គឺមាន មួយកន្លែងសំរាប់សាងសង់ អនុវិទ្យាល័យ និងវិទ្យាល័យ ដែលបានកំណត់ដោយឃុំ ហើយដីសាលានេះ វាស្ថិតនៅក្នុងដីលំនៅដ្ឋានភូមិ ដោយឃុំត្រៀមសំរាប់សាងសង់នាពេលខាងមុខ នៅពេលដែលមានចំនួយឧបត្ថម្ភពីសំណាក់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។

ចំពោះការអភិវឌ្ឍន៍ និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសង្គមនៅក្នុងមូលដ្ឋានឃុំ បច្ចុប្បន្ននៅមានកំរិត ហើយឃុំបច្ចុប្បន្នមានសាលាបឋមសិក្សា ៣សាលា ៦ថ្នាក់ ៩បន្ទប់ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយក៏ ការអភិវឌ្ឍន៍លើវិស័យអប់រំនៅក្នុង ឃុំសិរីមង្គល នៅពុំទាន់បំពេញបាននូវតម្រូវការ នៃការសិក្សានៅឡើយ ។ ដូច្នេះជាអទិភាពនៅគម្រោងផែនការ ១៥ ឆ្នាំ ខាងមុខតម្រូវការលើ អាគារសិក្សា ផ្អែកតាមបរិមាណ សិស្សានុសិស្ស គឺ សាលាមតេយ្យសិក្សាមាន

១ សាលា ៣បន្ទប់ ហើយចំនួនកុមារអាចកើនឡើងរយៈពេល១៥ឆ្នាំ ៥២៧នាក់ ចំណែក សាលា បឋមសិក្សា តម្រូវការត្រូវរៀបចំសាលា ២ បន្ថែមទៀត ស្មើនិង ១០ បន្ទប់ និងចំនួនសិស្សអាចកើនឡើង ទៅដល់ ១៧៣២ នាក់ដោយពុំកិតទៅលើចំនួនសិស្សដែលមានឆ្នាំ ២០០៩ ឡើយ ។ ហើយសាលាអនុវិទ្យាល័យតម្រូវ ការ ១សាលា ៦បន្ទប់បន្ថែមទៀត និងចំនួនសិស្ស អាចមានការកើនឡើង ១១១៧ នាក់ និងសាលាវិទ្យាល័យតម្រូវការ ២ សាលា ៨ បន្ទប់បន្ថែម នឹងចំនួនសិស្សអាចកើនឡើងដល់ទៅចំនួន ១០៩៤ នាក់ ។

តារាងកំណើនកុមារ និងតម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១២-២០២២

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយសិក្សា | ១១៥ | ០ | ១ | ១៨៩ | ០ | ១ | ២២៣ | ០ | ១ |
| ថ្នាក់បឋមសិក្សា | ៥២៨ | - | - | ៦៤៦ | ០ | - | ៧៦៤ | ២ | ១០ |
| ថ្នាក់អនុវិទ្យាល័យ | ២៩៥ | ០ | - | ៣៦០ | ១ | ៦ | ៤៦២ | ០ | - |
| ថ្នាក់វិទ្យាល័យ | ២៩៨ | ១ | ៣ | ៣៦៥ | ០ | ១ | ៤៣១ | ១ | ៤ |

## ២.៣.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

### ក. សេវាកម្មសុខភាព

បច្ចុប្បន្ននេះឃុំសិរីមង្គល មិនទាន់មានប៉ុស្តិ៍សុខភាពនៅតាមភូមិសំរាប់ជួយសំរួលនូវតម្រូវការ នៃការទ្រទ្រង់សុខមាលភាពរបស់ប្រជាពលរដ្ឋបន្ថែមលើមណ្ឌលសុខភាពឡើយ ចំណែកវេជ្ជបណ្ឌិត និងគ្រូពេទ្យព្យាបាលជំងឺទូទៅក៏ពុំទាន់មានគ្រប់គ្រាន់នៅឡើយដែរ ដែលជាហេតុនាំអោយ មានការខ្វះខាតចំពោះសេវាសុខាភិបាលពីព្រោះប្រសិនបើមានអ្នកជំងឺឈឺធ្ងន់ ត្រូវបញ្ជូនអ្នកជំងឺទាំងនោះទៅមណ្ឌលសុខភាពនៅទីរួមស្រុកដែលមានចំងាយផ្លូវ ២២គីឡូម៉ែត្រ ឬក៏ទៅមន្ទីរពេទ្យបង្អែក នៅទីរួមខេត្តរតនគីរី ដែលមានចំងាយឆ្ងាយរហូតដល់ ៦២ គីឡូម៉ែត្រ។ ដោយស្ថានភាពភូមិសាស្ត្រនៃឃុំដែលមានប្រជាជនរស់នៅដាច់ឆ្ងាយពីគ្នា និងមានចំងាយផ្លូវឆ្ងាយពីមណ្ឌលសុខភាពឃុំនិងពីឃុំមកខេត្តបណ្តាលអោយមានការលំបាក ក្នុងការធ្វើដំណើរ ហើយប្រជាពលរដ្ឋ តែងតែ ជួបប្រទះនូវ ប្រភេទជំងឺច្រើនប្រភេទដូចជានៅរដូវវស្សាប្រជាពលរដ្ឋតែងជួបប្រទះនូវជំងឺគ្រុនចាញ់ គ្រុនឈាម និងនៅរដូវប្រាំងតែងជួបប្រទះជំងឺរលាកផ្លូវដង្ហើមលើ និងផ្លូវដង្ហើមក្រោម ព្រមទាំងជំងឺរាគរូស ។

បច្ចុប្បន្នប៉ុស្តិ៍សុខភាពឃុំ កំពុងខ្វះអាគារសំរាប់អ្នកជំងឺសំរាកព្យាបាល ខ្វះគ្រូពេទ្យ និង វេជ្ជបណ្ឌិត សំរាប់ពិនិត្យ និងព្យាបាលជំងឺ ។ ដោយអ្នកជំងឺមនុស្សចាស់ និង កុមារសំរាកនៅជាមួយគ្នា ដែលជាហេតុនាំឱ្យមានបញ្ហាដល់សុវត្ថិភាពចំពោះអ្នកជំងឺ ពីព្រោះកុមារងាយទទួលឆ្លងជំងឺពីមនុស្សចាស់ និងម្យ៉ាងទៀតមានអ្នកជំងឺឈឺធ្ងន់ពុំមានគ្រូពេទ្យ ឬ វេជ្ជបណ្ឌិតពិនិត្យព្យាបាលជំងឺអោយបានដិតដល់ជាពិសេសស្ត្រីមានផ្ទៃពោះប្រហែល៦០%ជាចំនួន ដ៏តិចតួចដែលបានទទួលសេវាពីពេទ្យឆ្មបក្រៅពីនោះដែលជាចំនួនច្រើនសុទ្ធតែទទួលសេវាពីឆ្មបបុរាណ ។ ដោយឃុំមានប្រជាពលរដ្ឋពុំគ្រប់ចំនួនតាមបទដ្ឋាននៃស្តង់ដាដែលតំរូវឱ្យមានប្រជាពលរដ្ឋគ្រប់ចំនួនទើបអនុញ្ញាត ឱ្យបង្កើតអោយមានប៉ុស្តិ៍សុខភាពក៏ដោយក៏គួរបង្កើតឱ្យ មានប៉ុស្តិ៍សុខភាពនៅតាមភូមិពីព្រោះឃុំជាតំបន់ដាច់ស្រយាលនៅឆ្ងាយពីទីរួម

ខេត្ត ។ ដូច្នេះជាអទិភាព ឃុំត្រូវលើកផែនការសាងសង់ ប៉ុស្តិ៍សុខភាពអោយមាននៅតាមភូមិនីមួយៗ ទើបអាចជួយសំរាលដល់ការលំបាក លើការថែទាំសុខភាពក្នុងមូលដ្ឋាន ។

**ខ. ការផ្គត់ផ្គង់ទឹកស្អាត**

ការប្រើប្រាស់ទឹកស្អាតនៅក្នុងឃុំសិរីមង្គល បច្ចុប្បន្ន នៅតែជាបញ្ហាចំបង នៅឡើយ ព្រោះថាអ្នកភូមិបច្ចុប្បន្ន ពួកគាត់ពុំមានអណ្តូងទឹកស្អាតប្រើប្រាស់ទេ សព្វថ្ងៃប្រជាពលរដ្ឋនៅក្នុងឃុំសិរីមង្គលទាំងអស់នៅប្រើប្រាស់ទឹកអូរ និង ទឹកទន្លេសំរាប់ បរិភោគ ការដាំស្ល.... ហើយជាផែនការនៅពេលអនាគត ឃុំត្រូវបន្ថែមនូវ គម្រោងផែនការ ក្នុងការរៀបចំក្នុងការធ្វើអាងដើម្បីស្តុកទឹកស្អាត និង ព្រមទាំងផ្តល់ជូនធុងចម្រោះ ដើម្បីចែកចាយជូនប្រជាពលរដ្ឋ ប្រើប្រាស់ ។

ដើម្បីធានាបាននូវការប្រើប្រាស់ទឹកស្អាត សំរាប់ប្រជាជន នៅក្នុងឃុំសិរីមង្គល ទាំងមូលនោះឃុំមានគម្រោង ផែនការកសាងនូវបរិក្ខារទឹកស្អាត ដែលរួមមាន អណ្តូងស្នប់ ចំនួន ២០អណ្តូង សំរាប់ភូមិ ០៣ភូមិ និងផ្តល់ធុងចម្រោះ នៅក្នុងភូមិទាំង៣ ក្នុង១គ្រួសារ ១ ធុង។

## ២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា

នៅក្នុងការអភិវឌ្ឍន៏ ទៅលើផ្នែកវប្បធិមជាកត្តាមួយ ចូលរួមចំណែកជំរុញ អោយមានសន្ទុះដល់ការអប់រំ ផ្នែកព្រះពុទ្ធសាសនា ។ រាល់ទីតាំងនីមួយៗតាមបណ្តាភូមិ ត្រូវបានផ្តល់លទ្ធភាព និងជួយសំរួលដល់ប្រជាពលរដ្ឋ នៅតាមមូលដ្ឋានផ្ទាល់ មានឱកាសចូលរួម ពង្រីកលើការ ផ្សព្វផ្សាយតាមរយៈការអប់រំដល់យុវជនដែលជាសរសរទ្រូង នៃប្រទេសជាតិអោយជៀសផុតពីអំពើខុសច្បាប់ទាំងឡាយដែលរដ្ឋាភិបាលបានកំណត់។ បច្ចុប្បន្នសំរាប់ឃុំសិរីមង្គល កន្លែងគោរពប្រពៃណីសាសនានាថ្ងៃអនាគត ពុំទាន់បានគ្រប់តម្រូវការរបស់ប្រជា ពលរដ្ឋនៅឡើយទេ ។

<u>តារាងការអភិវឌ្ឍន៍ និងអភិរក្សផ្នែកវប្បធម៌ និងសាសនា</u>

| **វប្បធម៌ និងសាសនា** | **ចំនួនក្នុងឆ្នាំនេះ** | **ចំនួន១៥ឆ្នាំក្រោយ** | **បំរែបំរួល** |
|---|---|---|---|
| សាលាឆទាន | ០ | ០៣ | ០៣ |
| ទីកន្លែងសាការៈបូជា | ០ | ០៣ | ០៣ |
| វត្តអារាម | ០១ | ០២ | ០៣ |
| ផ្សេងៗ | | | |




**រូបភាពទី ១០:** វត្តគង្គាសោភិតនៅភូមិស្រែពកធំ

## ២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍

ផ្អែកតាមស្ថានភាពជាក់ស្តែងនៃបរិមាណផ្លូវដែលមានក្នុងឃុំសិរីមង្គល ឃើញថាផ្លូវមួយចំនួនត្រូវធ្វើការកែលំអរដូចជា ផ្លូវគ្រួសក្រហម ដែលមាននៅក្នុងឃុំសរុបចំនួន ១ ខ្សែ ដែលខ្សែទី ១គឺជាផ្លូវលំក្រាលគ្រួសក្រហមក្នុងឃុំ ហើយផ្លូវនេះមានទិសដៅពីឃុំទៅស្រុកកូនមុំមានប្រវែង៨៣០៦ម៉ែត្រ និងខ្សែទី ២ ផ្លូវលំតាមមាត់ទន្លេគឺជាប្រភេទផ្លូវលំជនបទមានប្រវែង ៨៤៥៣មែត្រហើយផ្លូវនេះ បច្ចុប្បន្នពុំទាន់បានក្រាលគ្រួសក្រហមនៅឡើយទេ ។ ដោយឡែកផ្លូវស្មើជើង និងផ្លូវរទេះនៅក្នុងឃុំមានច្រើនរហូតទៅ ដល់ ១៨ខ្សែ សរុបចំនួនប្រវែងផ្លូវស្មើនឹង ៥៤៧២៦ម៉ែត្រ ។ តាមការសិក្សាផ្លាស់ប្តូរយោបល់ជាមួយប្រជាជន និងក្រុមប្រឹក្សា ឃុំឃើញថាឃុំមានគំរោងសាងសង់ផ្លូវក្រាលគ្រួសក្រហមចំនួន ៣ខ្សែ ដែលខ្សែទី ១មានប្រវែង ៩២១០ ម៉ែត្រដែលផ្លូវខ្សែនេះ ត្រូវបានសាងសង់លើផ្លូវលំជនបទដែលមានស្រាប់ និងខ្សែទី២ ដែល ពីមុនជាផ្លូវរទេះ និងផ្លូវថ្មើរជើងដែលមានប្រវែង ៤៥៤៧ ម៉ែត្រ នឹងខ្សែទី ៣ ដែលកាលពីមុនជាផ្លូវលំជនបទ ដែលមានចំងាយ ៣៤០២ ម គឺពីភូមិនាងដី ទៅភូមិសាមខា ។

តារាងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំនេះ (គ.ម) | ប្រវែងផ្លូវ១៥ឆ្នាំ (គ.ម) | បំរែបំរួល |
|---|---|---|---|
| ផ្លូវក្រាលគ្រួសក្រហម | ៨,៣០៦ | ៨,៣០៦ | ៨,៣០៦ |
| ផ្លូវរទេះ/ថ្មើរជើង(ផ្លូវលំជនបទ) | ៥៤,៧៥៦ | ២៩.២៦១ | ២៥.៤៦៥ |
| ជួសជុលផ្លូវលំ១ខ្សែ | ៨,៣០៦ | ៨,៣០៦ | ៨,៣០៦ |
| ចំនួនស្ពានឈើ | ៤ កន្លែង | ៨ កន្លែង | ៤ កន្លែង |
| លូកាត់ផ្លូវ | ០៣ កន្លែង | ០៩ កន្លែង | ១២ កន្លែង |
| ប្រព័ន្ធធារាសាស្ត្រ | ០ | ២ កន្លែង | ២ កន្លែង |

# ជំពូក ៣
# ផែនការប្រើប្រាស់ដីពេលអនាគត
## ៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី
### ៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល

នៅក្នុងឃុំសិរីមង្គល ធនធានដែលមានស្រាប់អាចផ្តល់នូវសក្តានុពលភាពដល់ការប្រើប្រាស់ដី និង អភិរក្ស អភិវឌ្ឍន៍ ទៅលើធនធានទាំងនោះអោយមាននិរន្តរភាព ដែលក្នុងនោះរួមមានដូចជា :ស្ថានភាពដីដែលជាតំបន់ ដីមាន ជីជាតិ ដែលជាប្រភេទដីល្បាយខ្សាច់អាចម៏ជន្លេនពិណខ្មៅ ដែលអំណោយផលទៅលើដំណាំយុទ្ធសាស្ត្រ និងការធ្វើ កសិកម្មសំរាប់ជួយទ្រទ្រង់ដល់ការប្រកបមុខរបររស់នៅរបស់ប្រជាពលរដ្ឋ ។ ដោយឡែកធនធានធម្មជាតិ ដីសំបូរបែប ដែលផ្តល់នូវបរិស្ថានធម្មជាតិដ៏ល្អប្រសើរសំរាប់សត្វព្រៃ និង មច្ឆាជាតិរស់នៅព្រមទាំងពពួក ជីវៈចំរុះនៃប្រព័ន្ធ អេកូឡូស៊ី ដែលធ្វើអោយតំបន់នេះបានផ្តល់នូវសារៈប្រយោជន៍បំពេញអោយគ្នាទៅវិញទៅមក មិនត្រឹមតែប៉ុណ្ណោះ ធនធានដីសំបូរ បែបនេះបានជួយដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក្នុងការដកហូតអនុផលព្រៃឈើ ដូចជា វល្លិ ផ្តៅ ឫស្សី ឱសថបុរាណ និងប្រភេទឈើប្រណិត១ដូចជាបេង នាងនួន ទាល គគី ស្រឡៅ ដែលជាឈើសំរាប់ សំណង់ និងគ្រឿងសង្ហារឹមជាដើម សំរាប់បំរើការអោយក្នុងតំបន់ និងក្រៅតំបន់ ។

### ៣.១.២ តម្រូវការដីតាមប្រភេទ

ដោយផ្អែកទៅលើអត្រាកំណើនរបស់ប្រជាពលរដ្ឋមានការកើនឡើងដូចនេះតម្រូវការនៃការប្រើប្រាស់ទៅលើ ធនធានត្រូវមានការសិក្សា និងធ្វើការពិចារណានៃធនធានដែលមាននៅក្នុងឃុំ ដោយរៀបចំគម្រោងផែនការ ទៅលើ តម្រូវការពង្រីកដីលំនៅដ្ឋានសំរាប់សម្បទានសង្គមកិច្ច បានកំណត់នៅលើផ្ទៃដី ស្ថិតនៅបណ្តោយផ្លូវឆ្ពោះពីចំណុចអូរ ឡាំងអះឆ្ពោះទៅចំណុចផ្លូវបំបែកស្រែពកធំ និងស្រែពកតូចដែលមានទំហំ ២៣៨.៧៧ ហិកតា ។

និងមួយភាគទៀតជាដីស្រែរួមមាន ៥កន្លែង ដែលមានទំហំសរុប៨៩.១២ ហិកតា ដែលពឹងផ្អែកទៅលើទឹក ភ្លៀង ហើយដីកសិកម្មពនេចរមាន ៤ កន្លែងមានទំហំ ៥៥ ហិកតា ដោយឡែកដីកប់ខ្មោចមានទំហំសរុប ១ ហិកតា និង សហគមន៍ព្រៃឈើចំនួន ៣កន្លែងមានទំហំសរុប ២៤៨ ហិកតា ។

<u>តារាងតម្រូវការនៃការប្រើប្រាស់ដីពេលអនាគត</u>

| **ការប្រើប្រាស់ដីធ្លី** | **ក្រឡាផ្ទៃឆ្នាំនេះ( ហិចតា)** | **ក្រឡា ផ្ទៃ សំរាប់ ១៥ឆ្នាំ ខាងមុខ( ហិចតា)** | **បំរែបំរួល ( ហិចតា)** |
|---|---|---|---|
| ដីលំនៅដ្ឋានភូមិ | ៣៦ | ៣៤១ | ២៣៨ |
| ដីស្រូវវស្សា | ៧២៦ | ៨១៥ | ៨៩ |
| ដីកសិកម្មពនេចរ | ៦៦ | ១២១ | ៥៥ |

| | | | |
|---|---|---|---|
| សហគមន៍ព្រៃឈើ | 0 | ២៤៩ | ២៤៩ |
| ដីកប់ខ្មោច | 0 | ០៥ | ០៥ |
| ដីសាលារៀន | 0 | ០២ | ០២ |
| ដីវត្ត | 0 | ០៤ | ០៤ |
| សាលាឃុំ | 0 | ០៥ | ០៥ |
| ប៉ុស្តិ៍សុខភាព | 0 | ០១ | ០១ |

## ៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់

### ៣.២.១ ការវិភាគអន្តរអំពើ

ការគ្រប់គ្រងនិងបែងចែកសំរាប់ការប្រើប្រាស់ដី មានកត្តាដែលធ្វើអោយមានការផ្តល់នូវ ផលប្រយោជន៍ និង មាននិរន្តរភាពហើយនឹង មានការប៉ះពាល់ទៅលើផ្នែកមួយចំនួនដូចជា សេដ្ឋកិច្ច សង្គមកិច្ច និង បរិស្ថាន ដែលក្នុងនោះមានដូចជា :

**១-ដីលំនៅដ្ឋាន :**ការប្រែប្រួលពីព្រៃពាក់កណ្តាលស្រោង និងព្រៃរបោះអោយប្រែក្លាយទៅជាដីលំនៅដ្ឋាន សំរាប់សម្បទានសង្គមកិច្ចវាជាការជួយដល់ប្រជាពលរដ្ឋដែលខ្វះខាតដីសំរាប់សាងសង់លំនៅដ្ឋាន កត្តានេះវាជំរុញ អោយ ប្រជាពលរដ្ឋនាពេលបច្ចុប្បន្នក៏ដូចជាកូនចៅជំនាន់ក្រោយ មិនបានធ្វើចំណាកស្រុក ដែលអ្នកទាំងនេះ គឺជាទំពាំងស្នងឬស្សីសំរាប់ធ្វើការអភិវឌ្ឍន៍ឃុំរបស់ខ្លួន នាពេលខាងមុខ ។ ប៉ុន្តែកត្តាទាំងនេះវាបានធ្វើអោយប៉ះពាល់ដល់ព្រៃ ឈើ និងគំរបព្រៃឈើអោយបរិស្ថានប្រែប្រួល និងបាត់បង់ទីជំរករបស់សត្វព្រៃ ក៏ដូចជាសត្វស្រុកជាដើម ។

**២-ដីស្រូវវស្សា :** ការពង្រីកដីស្រែសំរាប់បង្កបង្កើនផលសំរាប់ទៅអនាគត ពីព្រៃរបោះរិចរិលនោះវាជាការប្រសើរ ហើយលើវិស័យកសិកម្មដែលជាកត្តាអំណោយផលដល់ការបង្កបង្កើនផល ក៏ដូចជាការលើកស្ទួយសេដ្ឋកិច្ចនៅក្នុងមូលដ្ឋាន និងជីវភាពក្នុងគ្រួសារប្រចាំថ្ងៃដែរ ។

**៣- ដីកសិកម្មពនេចរ :** ការប្រែប្រួលប្រភេទដីប្រសិនបើជាប្រភេទព្រៃរបោះរិចរិលមកជាដីសំរាប់ធ្វើកសិកម្មវិលជុំ នោះវាជាមោទនៈភាពសំរាប់ជួយបំពេញបន្ថែមលើការងារធ្វើស្រែដែលផ្តល់ផលប្រយោជន៍ ក្នុងការរកប្រាក់ចំណូល ជួយបំពេញបន្ថែមក្នុងការកាត់បន្ថយភាពក្រីក្រ ក្នុងជីវភាពគ្រួសារ ។

**៤- សហគមន៍ព្រៃឈើ :** ដោយយល់ឃើញថា ការបាត់បង់ព្រៃឈើ ធ្វើអោយបាត់បង់ប្រាក់ចំណូលប្រចាំជីវភាព និងធ្វើអោយអាកាសធាតុប្រែប្រួល ។ ប្រជាពលរដ្ឋនៅក្នុងឃុំសិរីមង្គលបានមូលមតិគ្នាត្រៀមបង្កើតសហគមន៍ព្រៃឈើ ចំនួន ៣កន្លែងសំរាប់ទុកប្រើប្រាស់តាមលក្ខណៈបច្ចេកទេស និងទុកអោយកូនចៅជំនាន់ក្រោយៗបានស្គាល់ និងបានយល់ដឹងពីសារៈប្រយោជន៍របស់ព្រៃឈើ និងសត្វព្រៃ ។

**៥- ដីកប់ខ្មោច :** ការព្រមព្រៀងគ្នារវាងសហគមន៍ឃុំ ភូមិដើម្បីចាត់តំបន់សំរាប់ធ្វើកន្លែងបូជាសាកសពរួមរឺកប់សាកសព គឺជាប្រពៃណីដែលមានភាពសាមគ្គីគ្នាសំរាប់ភូមិមួយ ទៅភូមិមួយផ្សេងទៀតផ្សេងៗគ្នា ប៉ុន្តែមិនត្រូវធំពេកទេគឺនៅក្បែរដីលំនៅដ្ឋាន ប៉ុណ្ណោះ ។

**៦-ដីសាលារៀន :** ដោយឡែកចំពោះការពង្រីកវិស័យអប់រំដោយផ្តោតទៅលើអាគារសិស្សា និងសាលាគឺជាការចាំបាច់បំផុតសំរាប់បង្កើនធនធានមនុស្សនៅក្នុងមូលដ្ឋាន ។

បច្ចុប្បន្នទោះបីឃុំមានការខ្វះខាត អាគារសិក្សាក៏ដោយ ក៏ឃុំមានសាលាបឋមសិក្សា ហើយបានកំពង់ស្នើសុំសាងសង់សាលាបន្ថែមទៀត ដើម្បីតម្រូវការកូនចៅបានចូលរៀនគ្រប់ៗគ្នា រីឯសាលាអនុវិទ្យាល័យ វិទ្យាល័យ និងមតេយ្យនៅក្នុងឃុំគឺពុំទាន់មាននៅឡើយ ដូច្នេះឃុំត្រូវតែព្យាយាមរកដំណោះស្រាយ យ៉ាងណាអោយបានព្រោះវាមានសារៈសំខាន់ និងជាមូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាលចំណេះដឹងបន្តទៅថ្ងៃមុខ ។

**៧- ដីវត្ត :** គឺជាដីដែលបានសាងសង់នូវវត្តអារាម សំរាប់ប្រជាជនក្នុងការគោរពបូជា និងធ្វើការអប់រំផ្នែកព្រះពុទ្ធសាសនាសំរាប់ប្រជាពលរដ្ឋនៅក្នុងឃុំមាន ឱកាសចូលរួមពង្រីកនឹងផ្សព្វផ្សាយតាមរយៈការអប់រំដល់យុវជនដែលជាសរសរទ្រូងរបស់ប្រទេសជាតិអោយជៀសផុតពីអំពើរខុសច្បាប់ទាំងឡាយ ។ នៅក្នុងឃុំសិរីមង្គលមានគំរោងទុកដីសំរាប់សាងសង់វត្តអារាម នៅពេលអនាគតគឺខាងកើត ឈាងខាងត្បូង (ដីគ្រោងសាងសង់សាលាឃុំ) ត្រង់ចំណុចផ្លូវបំបែកស្រែពកតូច និងស្រែពកធំ ។

**៨- សាលាឃុំ:** គឺបានប្រែប្រួលពីរតំបន់ព្រៃរបោះរិចរិលត្រង់ចំណុចផ្លូវបំបែកស្រែពកតូច និងស្រែពកធំចំណុចច្រមុះជ្រូកមានគំរោងសាងសង់សាលាឃុំនៅទីនោះដើម្បីធ្វើការងារលើគ្រប់វិស័យដែលមាននៅឃុំ ជាពិសេសអប់រំប្រជាពលរដ្ឋអោយគោរពច្បាប់ និងចេះសាមគ្គីគ្នាដើម្បីធ្វើការអភិវឌ្ឍន៏ឃុំ ភូមិអោយបានរីកចំរើននាពេលអនាគត ។

**៩- ប៉ុស្តិ៍សុខភាព :** ឃុំមានគំរោងសាងសង់ប៉ុស្តិ៍សុខភាពបន្ថែមទៀត នៅលើដីគ្រោង សាងសង់លំនៅដ្ឋានថ្មីដែលបច្ចុប្បន្នមានប៉ុស្តិ៍សុខភាពមួយកន្លែងរួចទៅហើយ ស្ថិតនៅក្នុងភូមិស្រែពកធំ ដើម្បីជួយដល់បងប្អូនប្រជាពលរដ្ឋដែលមានជំងឺឈឺស្កាត់ និងចុះជួយអប់រំបន្ថែមដល់ប្រជាពលរដ្ឋតាមបណ្តាភូមិអោយចេះថែរក្សាសុខភាពដើម្បីប្រកបរបរនៅក្នុងគ្រួសារ ក៏ដូចជាការកាត់បន្ថយភាពក្រីក្រនៅក្នុងមូលដ្ឋាន។

**១០- ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ :** ការសាងសង់ផ្លូវគឺជាការសំរួលដល់ការធ្វើដំណើរ និងចរាចរគ្រប់ប្រភេទហើយនឹងការចូលរួមក្នុងការកាត់បន្ថយចំណាយលើការដឹកជញ្ជូន ។ ការអភិវឌ្ឍន៍ថ្មីត្បិតតែមានការដោះស្រាយ និងហេតុប៉ះពាល់ក៏ដោយប៉ុន្តែវាផ្តល់នូវផលប្រយោជន៍ច្រើនដើម្បីប្រើប្រាស់ ។

១១- ប្រព័ន្ធធារាសាស្រ្ត : ការសាងសង់ប្រឡាយដល់ការស្រោចស្រពជាកត្តាផ្តល់នូវសារៈប្រយោជន៍ក្នុងការបង្កើននូវប្រាក់ចំណូលតាមរយៈការបង្ករបង្កើនផល និងដំណាំរួមផ្សំ ។

### ៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត

### ៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី

**១/ដីលំនៅដ្ឋាន**

**- ក្បាលដី F១២០០:**

ដីនេះមានតំបំសរុប ២៣៨ ហិកតារួមមាន១កន្លែង រាងជាចតុកោណកែង អមសងខាង ផ្លូវរទេះ រឺផ្លូវដើរថ្មើរជើងមានទទឹង ២៧០មបណ្តោយប្រវែង ៣៧៩២មអមសងខាងផ្លូវ ។ បច្ចុប្បន្នដីលំនៅដ្ឋានសំរាប់ អនាគតគឺជាដីព្រៃឈើដែលក្នុងនោះមានដីព្រៃស្រោងសើមចំនួន ៣.២២ ហិកតា ដីព្រៃរបោះចំនួន ២០២ ហិកតា និង ព្រៃដុះឡើងវិញចំនួន ៣៣.៥ ហិកតា ហើយភូមិនាងដីដែលប្រជាពលរដ្ឋនៅក្នុងឃុំសិរីមង្គលត្រៀមបំរុងសំរាប់លំនៅដ្ឋានពេលអនាគត រឺក៏ជាកន្លែងដែលបំលាស់ទីពីទឹកជំនន់

បញ្ញត្តិនៃការប្រើប្រាស់ដីគឺ :

- ត្រូវរក្សាទុកចំណីផ្លូវតាមច្បាប់កំណត់
- ជំរៅដីសំរាប់លំនៅដ្ឋានមិនអាចលើពី ១០០ម គិតពីអ័ក្សផ្លូវ ។

**- ក្បាលដី FIP២៩-០១: ដីសំរាប់សាងសង់វត្ត**

ដីសំរាប់វត្ត មួយកន្លែងដែលមានទំហំ ៥ហិកតា ជាដីដែលឃុំបានគ្រោងសំរាប់ធ្វើវត្ត សំរាប់ប្រជាជន ក្នុងការគោរពបូជា និងការអប់រំផ្នែកព្រះពុទ្ធសាសនា ដែលឃុំបានផ្តល់លទ្ធភាព និងជួយសំរួលដល់ប្រជាពលរដ្ឋនៅក្នុង ឃុំមានឱកាសចូលរួម ពង្រីកលើការ ផ្សព្វផ្សាយតាមរយៈការអប់រំដល់ យុវជនដែលជាសរសរ ទ្រូងនៃប្រទេសជាតិអោយជៀសផុតពីអំពើខុសច្បាប់ទាំងឡាយ ។

**- ក្បាលដី FIP៤៤-០១ និង FIP៤៥-០១ ដីសំរាប់សាងសង់សាលាឃុំ និងប៉ុស្តិ៍រដ្ឋបាលឃុំ**

ដីសំរាប់សាងសង់សាលាឃុំ និងប៉ុស្តិ៍រដ្ឋបាលឃុំ មានទំហំ ៥ ហិកតា ដែលស្ថិតនៅតាមដងផ្លូវលំត្រង់ចំណុចផ្លូវបំបែកទៅភូមិស្រែពកតូចហើយដីនេះឃុំបានត្រៀមសំរាប់សាងសង់សាលាឃុំនិងប៉ុស្តិ៍រដ្ឋបាលឃុំ ដោយសព្វថ្ងៃឃុំពុំទាន់មានការិយាល័យសំរាប់ធ្វើការនៅឡើយ ដូច្នេះឃុំតម្រូវអោយមានជាចាំបាច់សំរាប់បំរើប្រយោជន៍ជាសាធារណៈ ។

**- ក្បាលដី FHL៥-០១ និង FIP៣០-០១ សំរាប់សាលារៀន និងប៉ុស្តិ៍សុខភាព**

ដីសាលារៀន និងប៉ុស្តិ៍សុខភាពឃុំក៏បានគ្រោងដីទុកចំនួន ២កន្លែង តែចំពោះទំហំមិនទាន់ច្បាស់លាស់នៅឡើយទេ ដោយសារដីសាលារៀន និងដីប៉ុស្តិ៍សុខភាពជាដីស្ថិតនៅជាមួយដីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ។

**២/ដីកន្លែងគប់ខ្មោច**

**- ក្បាលដី F១៣២០:**

ដីនេះមានទំហំ ៥ ហិកតា មាន២កន្លែងមានរាងជាចតុកោណកែង មួយទៀតរាងពងក្រពើទ្រវែង នៅខាងកើត ឈៀងខាងលិចភូមិជាប់ ម្ខាងផ្លូវដើរដែលមានទទឹង ៥០ បណ្តោយ ២០០ម៉ែត្រ ។ បច្ចុប្បន្នដីនេះមានពាក់ព័ន្ធ នឹងដីព្រៃ

ឈើនៅក្នុងនោះមានដី ព្រៃចំរុះស្រោង និងរបោះចំនួន ០.១៥ A និងព្រៃរបោះសុទ្ធចំនួន ៣.៤២ ហិកតា វាលស្មៅ ០.៥៥ A ។

## ៣-ដីស្រូវទស្សា

**- ក្បាលដី F២១១០**

ដីនេះមានសរុបទំហំ ២៤៩ហិចតា មាន៤កន្លែងនៅព័ទ្ធជុំវិញភូមិត្រៀមបំរុងបង្កើតថ្មីប៉ុន្តែនៅខាងលិចឈាង ខាងជើងនៃលំនៅដ្ឋានបច្ចុប្បន្នដែលជាដីទំនាប មានល្បាយអាចម៍ជន្លេនពណ៌ខ្មៅ ដែលស្ថិតនៅក្នុងតំបន់ព្រៃ របោះចំនួន ១៩.៣១ហិចតា និងផ្ទៃដីព្រៃដុះឡើងវិញចំនួន៦៩.៧២ហិចតា ។

## ៤-ដីកសិកម្មពនេចរ

**- ក្បាលដី F២៤០០**

ដីនេះមានទំហំសរុប ៥៥.៧១ហិចតា មាន៤កន្លែងដែលបងប្អូនប្រជាពលរដ្ឋរស់នៅក្នុងឃុំសិរីមង្គលបាន និង កំពុងធ្វើស្រែចំការ តាមលក្ខណះប្រពៃណីរបស់ពួកគាត់ដូចបានដាំដំណាំរយះពេលខ្លីសំរាប់ផ្គត់ផ្គង់ជីវភាព ហើយដី កសិកម្មពនេចរ ទាំងអស់នេះភាគច្រើនស្ថិតនៅក្នុងដីព្រៃឈើ ក្នុងនោះមានដីព្រៃរបោះសរុបចំនួន៥៥.៧១ ហិចតា ដែល ជាដីសាធារណៈរបស់រដ្ឋ ។

## ៥-សហគមន៍ព្រៃឈើ

**- ក្បាលដី F3710**

ដីនេះមានទំហំសរុបចំនួន ៨៩ហិចតា មាន៣កន្លែង ដែលបងប្អូនប្រជាពលរដ្ឋត្រៀម និងបង្កើតសហគមន៍ ព្រៃឈើនៅពេលខាងមុខដើម្បីការពារនូវសម្បត្តិធម្មជាតិ ទុកសំរាប់ក្មេង១ជំនាន់ក្រោយដែលក្នុងនោះមានព្រៃស្រោង សើមចំនួន ៤១.១៩ហិចតា ព្រៃរបោះ ២០៧.១៨ហិចតា និងព្រៃដុះឡើងវិញចំនួន០.៥៥ហិចតា ។

តារាងតម្រូវការតាមប្រភេទដីអនាគត

| ល.រ | ឈ្មោះក្បាលដី | លេខកូដក្បាលដី | ក្រឡាផ្ទៃសំរាប់១៥ឆ្នាំខាងមុខ( ហិចតា) | ចំនួនកន្លែង |
|---|---|---|---|---|
| ០១ | ដីលំនៅដ្ឋានភូមិ | F1200 | ២៣៨ | ១ |
| ០២ | ដីកប់ខ្មោច | F1300 | ៥ | ២ |
| ០៣ | ដីស្រូវវស្សា | F2110 | ៨៩ | ៣ |
| ០៤ | ដីកសិកម្មពនេចរ | F2400 | ៥៥ | ៤ |
| ០៦ | សហគមន៍ព្រៃឈើ | F3710 | ២៤៩ | ៥ |

ឃុំសិរីមង្គល ថ្ងៃ 02 ខែ 04 ឆ្នាំ២០10

**មេឃុំ**

**ម៉ឺន–ស្រ៊ិន**

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូន ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តរតនគីរី

"ដើម្បីមេត្តាពិនិត្យ និងសំរេច"

កូនមុំ ថ្ងៃ 05 ខែ 04 ឆ្នាំ ២០10

**អភិបាលនៃគណៈអភិបាលស្រុក**

**និងជាប្រធានក្រុមការងារដីរដ្ឋ**

**ស្រុកកូនមុំ**

**ឈឿន ចាន់ឆាង**

**បានឃើញ និង ឯកភាព**

រតនគីរី ថ្ងៃ 21 ខែ 05 ឆ្នាំ ២០10

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ**

**ខេត្តរតនគីរី**

**ប៉ាវ–ហមផាន**

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖  ការពិពណ៌នាអំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ២៖  ស្ថានភាពនៃការគ្រប់គ្រង  និងកាន់កាប់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ៣៖  បញ្ហាពាក់ពន្ធ័ក្នុងការប្រើប្រាស់ដី

ឧបសម្ព័ន្ធ៤៖  ក្រុបខ័ណ្ឌនៃការអភិវឌ្ឍន៍

ឧបសម្ព័ន្ធ៥៖  បញ្ជីគំរោង

ឧបសម្ព័ន្ធ៦៖  ផែនទីប្រើប្រាស់ដីលំអិតនៅក្នុងឃុំ

ឧបសម្ព័ន្ធ៧៖  ផែនទីប្រើប្រាស់ដីសាមញ្ញនៅក្នុងឃុំ

ឧបសម្ព័ន្ធ៨៖  ផែនទីប្រើប្រាស់ដីអនាគតនៅក្នុងឃុំ  ឆ្នាំ២០០៩-២០២២

## ឧបសម្ព័ន ១

## ការពិពណ៌នា អំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្នឃុំសិរីមង្គល

- **ដីលំនៅដ្ឋានភូមិ:**

**ដីភូមិលាយសួនដំណាំ :**

ដីភូមិលាយសួនដំណាំ នៅក្នុងមូលដ្ឋានឃុំសិរីមង្គលគឺជាដីស្ថិតនៅតាមដងទន្លេស្រែពកសងខាង ដែលមានស្ថានភាព ជាដីខ្ពង់រាបពីធម្មជាតិតាំងពីដូនតារៀងមក។ ដីភូមិនេះត្រូវបានដាំនូវដំណាំរួមផ្សំជាច្រើន ដូចជា ចេក ដូង ដំឡូង ស្វាយ អំពិល ល្មុត ខ្នុរ ម្ទេស ស្ពៃ ននោង ត្រឡាច ល្ពៅ ស្លឹកគ្រៃ ....។ល។ ក្រៅពីនេះ ដីភូមិលាយសួន ដំណាំ មួយភាគជាដី ស្ថិតនៅជាប់គ្នា តាមបណ្តោយផ្លូវលំឬផ្លូវក្រាលគ្រួសក្រហមមកទីរួមស្រុកកូនមុំ។

ស្ថានភាពជាក់ស្តែងនៅឃុំសិរីមង្គល គឺអំណោយផលដោយធម្មជាតិព្រោះដីភូមិលាយសួនដំណាំនេះបានទទួលឥទ្ធិពលពីទឹកទន្លេស្រែពក ដែលអាចអោយប្រជាជនដាំដំណាំបានទាំងរដូវប្រាំងនិងរដូវវស្សា។ចំណែកដីលាយសួនដំណាំនៅតាមដងផ្លូវវិញគឺមានតិចតួចនៅរដូវប្រាំង។

**ដីស្រែវស្សា :**

ដីស្រែវស្សាវនៅក្នុងឃុំសិរីមង្គលមានទំហំសរុប ៧២៦ ហិកតា ហើយភាគច្រើនជាដី ដែលស្ថិតនៅជាប់គ្នាខ្លះ នឹងខ្លះទៀតស្ថិតនៅឆ្ងាយពីគ្នា ហើយនៅឆ្ងាយពីភូមិ អាចពី ១គីឡូម៉ែត្រ ទៅ ១០គីឡូម៉ែត្រពីភូមិ។ ប្រភេទដីស្រែវស្សានេះភាគច្រើននៃប្រជាពលរដ្ឋនៅ ឃុំសិរីមង្គលប្រើសំរាប់តែធ្វើស្រែវស្សានៅរដូវវស្សាតែមួយមុខគត់ពោល គឺពុំមានប្រើប្រាស់សំរាប់ដំណាំអ្វីផ្សេងនោះទេ។ ជាទូទៅដីស្រែវស្សាប្រភេទនេះមានទំហំពី ១ ហិកតា ទៅ ២ហិកតា ប៉ុណ្ណោះ ។

ដូច្នេះបើពិនិត្យទៅលើលទ្ធភាពនៃការប្រើប្រាស់ដីឃើញថា ពុំមានតុល្យភាពទៅ នឹងកំណើន និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនោះទេ ប្រការនេះឃុំបានគិតគូរក្នុងការបង្កើនផលិផលលើវិស័យកសកម្ម ដោយស្នើសុំអោយមានវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មអោយបានដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

**ដីកសិកម្មពនេចរ :**

ដីកសិកម្មពនេចរនៅក្នុងឃុំសិរីមង្គលសំដៅលើដីចំការផ្លាស់វេនដែលមាន ទំហំ៦៦ ហិកតា ដំណាំដែលក្នុងនោះរួមមានចំការដំណាំស្រូវ និង ដំណាំរួមផ្សំផ្សេងៗទៀតរួមមានបន្លែបង្កាគ្រប់ប្រភេទ និងមិនមានអោយដាំដំណាំដើមឈើហូបផ្លែ និងដំណាំយុទ្ធសាស្ត្រទេ ព្រោះដីចំការវិលជុំនេះពួកគាត់ធ្វើតែរយៈពេល២ឆ្នាំប៉ុណ្ណោះ ដែលក្នុងឆ្នាំទី១ ដំណាំស្រូវទទួលបានទិន្នផលខ្ពស់ចំណែកនៅឆ្នាំទី២ ផលស្រូវថយចុះបើធៀប នឹងឆ្នាំទី១។

បន្ទាប់ពីនោះ គឺពួកគាត់បន្តទៅធ្វើនៅកន្លែងផ្សេងទៀត ដែលដីនោះបានបោះបង់អស់រយៈពេល ៥ឆ្នាំមុននេះ បានក្លាយជា ដីដុះដើមឈើឡើងវិញនិងមាន ជីវជាតិ ។

ដីកសិកម្មពនេចរគឺសំរាប់បងប្អូនជនជាតិភាគតិចដែលការគ្រប់គ្រងនិងកាន់កាប់ទៅតាមជំនឿ និងប្រពៃណី របស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។ ចំការប្រភេទនេះច្រើកាប់នៅចំងាយពី២គ.មទៅ៣គ.មពីភូមិ ហើយចំការ ប្រភេទនេះពេលអនាគតនឹងក្លាយទៅជាដីលំនៅដ្ឋានអចិន្ត្រៃយ៍របស់ប្រជាពលរដ្ឋនៅក្នុងឃុំ។

**ព្រៃរបោះ :**

ព្រៃនេះរួមបញ្ចូលព្រៃរបោះចំរុះស្ងួត និងប្រភេទព្រៃ DIPTERCARP ស្ងួតមានទំហំ ៣៦៣៨១ ហិកតា ព្រៃប្រភេទនេះសំបូរភាគច្រើនដើមឈើ ខ្លុង ត្បែង ស្រឡៅ ត្រាច ធ្នឹក ព្រៃរបោះជ្រុះស្លឹកស្ទើរតែទាំងស្រុងនៅរដូវ ប្រាំង ។ព្រៃប្រភេទនេះងាយទទួលការរងគ្រោះដោយភ្លើងឆេះបើប្រៀបធៀបនឹងប្រភេទព្រៃផ្សេងទៀត ។លក្ខណៈ ធម្មជាតិព្រៃ DIPTERCARP ស្ងួតមានភាពរហាលឬចំហរ ប្រសិនបើពុំមានការរំខាន ព្រៃរបោះ អាចមានគំរប កន្ទ្បោមស្លឹកត្រឹមតែ៤០%ដី និងវាលស្មៅអាចមានឥទ្ធិពលសំខាន់លើការសំគាល់ព្រៃប្រភេទនេះ។ នៅរដូវប្រាំង វាមានការពិបាកក្នុង ការញែកប្រភេទព្រៃរបោះចេញពីព្រៃគម្លោធ។

**ព្រៃស្រោងស្ងួត :**

ព្រៃស្រោងស្ងួតនៅក្នុឃុំសិរីមង្គលមានទំហំ ៤៩០៩ ហិកតា ជាប្រភេទព្រៃញ៉ាតមានឈើធំៗនិងមាន ច្រើន ស្រទាប់ ហើយប្រភេទដើមឈើរក្សានូវស្លឹករបស់វាពេញមួយឆ្នាំ ។ ព្រៃប្រភេទនេះរួមបញ្ចូលទាំងព្រៃតំបន់ ទំនាប ត្រូពិច ព្រៃបៃតងតំបន់ភ្នំ ព្រៃបៃតងស្ងួត និងមានគំរបព្រៃក្រាស់ៗដែលអាចរក្សាបានសំណើមបានយូរ ។

**ព្រៃស្រោងសើម :**

ព្រៃស្រោងសើមនៅក្នុឃុំសិរីមង្គលមានទំហំប្រមាណ ៦៤៣ ហិកតា ជាប្រភេទព្រៃញ៉ាតមានឈើធំៗ និង មានច្រើនស្រទាប់ហើយរក្សាស្លឹករបស់វាបានពេញមួយឆ្នាំ ព្រៃប្រភេទនេះសំបូរទៅដោយដើមឈើប្រណិតៗហើយ ព្រៃ ប្រភេទនេះច្រើនមាននៅតំបន់ភ្នំ និងនៅតាមមាត់អូរ ។

**ព្រៃចំរុះ( ស្រោង និងរបោះ) :**

ព្រៃចំរុះ (ស្រោង និងរបោះ)នៅក្នុងឃុំសិរីមង្គមានទំហំ ៣៨៦១ ហិកតាព្រៃប្រភេទនេះជាការរាប់បញ្ចូល ព្រៃស្រោង និងប្រភេទឈើនៃព្រៃរបោះ ហើយភាគរយនៃព្រៃស្រោងប្រែប្រួលពី ៣០% ទៅ ៧០% ។ ព្រៃចំរុះ មានពណ៌បៃតងពេញមួយឆ្នាំទោះបីជាព្រៃរបោះមានច្រើនលើសលប់ក៏ដោយ ។

**ព្រៃដុះតាមមាត់ទឹក( អូរ ស្ទឹង)**

ព្រៃដុះតាមមាត់ទឹក(អូរ ស្ទឹង)នៅក្នុងឃុំសិរីមង្គមានទំហំសរុប ៥០៤៨ ហិកតាព្រៃប្រភេទនេះភាគច្រើន ជាប្រភេទ ដើមរុក្ខជាតិ ដូចជាដើមឫស្សី ដើមត្រាវព្រៃ,ស្ពាយ,ស្មោរ និងដើមឈើដែលមានស្លឹកពណ៌ខៀវស្រងាត់ ហើយព្រៃ ដែលដុះតាមមាត់ទឹកនេះវាជួយទ្រទ្រង់នូវជីវចំរុះ និងមច្ឆាជាតិពងនៅរដូវទឹកឡើង ឬរដូវវស្សា និងសត្វព្រៃមកលេងនៅទីនេះ ផងដែរ ។

**វាលភក់**

វាលភក់នៅក្នុងឃុំសិរីមង្គលមានទំហំសរុប ៥០៧ ហិកតា តំបន់នេះមានទឹកដក់នៅរដូវវស្សា និងនៅរដូវប្រាំង តំបន់នោះខ្លះស្ងួតហួតហែង ខ្លះអាចមានទឹកដក់តិចៗ ដែលអាចជួយទ្រទ្រង់ ទៅដល់ពពួកសត្វព្រៃមករកស៊ី និងលេង ។ ដី វាលភក់ជាដីដែលពុំមានជីជាតិទេ តែវាមានទំនាក់ទំនង និងការបំពេញអោយគ្នាទៅវិញទៅមក ជាមួយសត្វ ក៏ដូចជាជីវៈចំរុះគ្រប់ប្រភេទដែលមាននៅតំបន់នេះ ។

**បឹងធម្មជាតិ**

បឹងនៅក្នុងឃុំសិរីមង្គលរួមមាន ៣កន្លែង ដែលមានទំហំផ្ទៃទឹកសរុប ១៤ ហិកតា រួមមានបឹងត្រោះ បឹងគ្រួស និងបឹងច្រេស ដែលស្ថិតនៅភាគខាងជើងឈាងខាងកើតនៃឃុំ ដែលជា ជាកត្តា ផ្តល់នូវ លក្ខណៈងាយស្រួលក្នុងការផ្តល់នូវការប្រើប្រាស់ដល់ ប្រជាពលរដ្ឋក្នុងការស្រោចស្រប់ ស្រែ និង សត្វ ផ្សេងៗ ពិសេស ផ្តល់ នូវ ម្ហូបអាហារទៀតផង ។ ហើយម្យ៉ាងទៀតបឹងនេះក៏បានផ្តល់នូវផលត្រីយ៉ាងច្រើន ដែលជួយទ្រទ្រង់ ដល់ប្រជាជននៅក្នុងឃុំ និងសំរាប់សត្វស្រុក និងសត្វព្រៃគ្រប់ប្រភេទប្រើប្រាស់នៅរដូវប្រាំង ។

**អូរ ទន្លេ:**

ទន្លេស្រែពកមានប្រភពចេញមកពី ទន្លេសេសាន ផ្នែកនៃទន្លេស្រែពក ដែលភាគច្រើនមានទឹករាក់នៅរដូវប្រាំង ចំណែកឯនៅរដូវវស្សាទឹកឡើងកំពស់ខ្លាំង ដែលជាហេតុបណ្តាលអោយប៉ះពាល់ដល់ប្រជាជន ស្ថិតនៅតាមដងទន្លេ និងប៉ះពាល់ដល់ផលដំណាំកសិករ ។ ក្រៅពីទន្លេនៅមានអូរជាច្រើនទៀតដែលជាប្រភពទឹកសំរាប់ការប្រើប្រាស់ប្រចាំថ្ងៃ និងជាប្រភពសំរាប់ប្រើប្រាស់សំរាប់ដំណាំចំការ និងការធ្វើស្រែ ។ ដោយឡែកទន្លេនេះក៏សំបូរមច្ឆាជាតិរស់នៅ ដែលជាប្រភពចំណូលសេដ្ឋកិច្ចរបស់ឃុំមួយផ្នែកធំផងដែរ ។

**ព្រៃដុះឡើងវិញ :**

ប្រភេទព្រៃដុះឡើងវិញនៅក្នុងឃុំសិរីមង្គលមានទំហំ ១១៥៦ ហិតា ព្រៃដុះឡើងគឺជាព្រៃដែលបានកាប់ឬរិចរិល ហើយត្រូវបាន ដុះឡើវិញដោយស្រទាប់កូនឈើតូចៗដែលដុះឡើងវិញជាថ្មី ម្តងទៀតបន្ទាប់ពីបានកាប់រានធ្វើចំការពនេចរអស់មួយរយៈពេលមក អាចនិយាយបានថាជាតំបន់នៃដំណុះព្រៃចាស់ៗឡើងវិញ និងមានពណ៌ខៀវខ្ចី។

**ព្រៃគម្លោចលាយដើមឈើធំមួយៗ :**

ព្រៃគម្លោចលាយដើមឈើធំមួយៗមានទំហំ ៨៩២ ហិកតាជាប្រភេទដីដែលដុះស្មៅដែលមានពណ៌ស្រស់បំព្រងនៅរដូវវស្សា និងអស់សោភ័ណ្ឌភាពនៅរដូវប្រាំងចូលមកដល់ ព្រៃប្រភេទនេះក៏មានដើមឈើធំមួយៗ ដែលសំបូរទៅដោ ពពួកថ្មតូចៗ និងព្រៃគម្លោចពណ៌បៃតងជានិច្ច និងព្រៃគម្លោចស្ងួត ។

**ដីវាលស្មៅ :**

ដីប្រភេទវាលស្មៅនៅឃុំសិរីមង្គលមានទំហំ ២៧ ហិកតាដែលមួយផ្នែកជាប្រភេទដីស្រែដែលគេបានបោះបង់ចោល និងមួយផ្នែកទៀតជាសំបូរទៅដោយពពួករុក្ខជាតិស្មៅព្រិច និងស្មៅគម្លោធ ដីព្រៃវាលស្មៅប្រភេទ នេះពុំសូវសំបូរទៅដោយជីជាតិច្រើនទេ តែវាអាចទាក់ទាញ នូវប្រភេទសត្វព្រៃ ចូលចិត្តមករស់នៅព្រោះជាកន្លែងសំបូរចំណីអាហារ តែងាយរងគ្រោះដោយភ្លើងឆេះនៅរដូវប្រាំង ។

| | | |
|---|---|---|
| 1 | Code : 1200<br>ដីលំនៅដ្ឋានលាយសួនដំណាំ |  |
| 2 | Code : 2110<br>ស្រែវស្សា |  |

| | | |
|---|---|---|
| 3 | Code : 2400<br>ដីកសិកម្មពនេចរ : |  |
| 4 | Code : 3210<br>ព្រៃរបោះ : |  |
| 5 | Code : 3220<br>ព្រៃស្រោងស្ងួតៈ |  |

| | | |
|---|---|---|
| 6 | Code : 3120<br>ព្រៃស្រោងសើម : |  |
| 7 | Code : 3300<br>ព្រៃចំរុះ (ស្រោង និងស្ងួត): |  |
| 8 | Code : 3310<br>ព្រៃដុះតាមមាត់ទឹក |  |

| | | |
|---|---|---|
| 9 | Code : 5300<br>វាលភក់ |  |
| 10 | Code : 5110<br>បឹង |  |
| 11 | Code : 5210<br>ទន្លេ |  |

| | | |
|---|---|---|
| 12 | Code : 3400<br>ព្រៃដុះឡើងវិញ |  |
| 13 | Code : 4600<br>ព្រៃគម្លោធលាយដើមឈើធំមួយៗ : |  |
| 14 | Code : 4100<br>វាលស្មៅ : |  |

# ឧបសម្ព័ន្ធ ២

## ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន (ដែនទីA-3)

| លរ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី (ហត) | ផ្សេងៗ |
|---|---|---|---|
| ១ | តំបន់ជំរកសត្វព្រៃលំផាត់ | ៤៣៤១៨ | តំបន់នេះត្រូវបាន ការពារសត្វព្រៃគ្រប់ប្រភេទ និងបរិស្ថានហើយមានការគ្រប់គ្រងដោយបរិស្ថាន ។ |
| | ព្រៃរបោះ | ២៨៣៦៤ | ៤៥ កន្លែង |
| | ព្រៃស្រោងស្ងួត | ៤៥១១ | ២១ កន្លែង |
| | ព្រៃស្រោងសើម | ៩៧ | ៩ កន្លែង |
| | វាលស្មៅ | ២៤ | ៤ កន្លែង |
| | វាលភក់ | ២៧៧ | ១៨ កន្លែង |
| | ព្រៃចំរុះ | ៣៨៤៤ | ៩ កន្លែង |
| | ព្រៃដុះតាមមាត់ទឹក | ៤៨៣៦ | ១៥ កន្លែង |
| | ទន្លេ ស្ទឹង អូរ | ១៦៥ | ១ កន្លែង |
| | ព្រៃដុះឡើងវិញ | ១៦៩ | ៦ កន្លែង |
| | ព្រៃគម្លោចលាយដើមឈើធំមួយៗ | ៨៩១ | ១៨ កន្លែង |
| | ដីកសិកម្មពនេចរ | ៤៣ | ៥ កន្លែង |
| | ស្រូវវស្សា | ១៩៧ | ៣៣ កន្លែង |
| ២ | អន្លង់អភិរក្សទន្លេស្រែពក | ៤ | ៣ កន្លែង (កន្លែងទី ១អន្លង់កំពង់អក ទី២អន្លង់ពុំរ៉ែ ទី ៣ អន្លង់បាក់រទេះ) |

ប្រភព: ទិន្នន័យGIS ប្រមូលពីមន្ទីរជំនាញពាក់ព័ន្ធជុំវិញខេត្តរតនគិរី

## ឧបសម្ព័ន្ធ ៣

## តារាងបញ្ហា មូលហេតុ ដំណោះស្រាយ

| បញ្ហា | ទីតាំង | មូលហេតុ | តំរូវការ | ឧបសគ្គ | ដំណោះស្រាយ | យោបល់ជន |
|---|---|---|---|---|---|---|
| ១ | ២ | ៤ | | | ៥ | |
| ត្រីមានការថយចុះ | ៣ភូមិ | ការនេសាទខុសច្បាប់ | មានម្ហូបអាហារហូបគ្រប់គ្រាន់ដោយត្រីសំបូរឡើងវិញ ។ | | ជីស្រះចញ្ចឹមត្រីជាលក្ខណៈគ្រួសារ ផ្តល់ពូជត្រី ផ្សព្វផ្សាយច្បាប់ជលផល ទប់ស្កាត់ការប្រើឧបករណ៍នេសាទខុសច្បាប់ ។<br>រៀបចំបញ្ហាផ្ទៃក្នុងសំរាប់ក្រុមអ្នកទទួលផល ។<br>ឡើងទឹកចិត្តការចិញ្ចឹមត្រីតាមត្រពាំងធម្មជាតិ និង ជាលក្ខណៈគ្រួសារ<br>ផ្តល់សត្វស្រុកចិញ្ចឹមតាមគ្រួសារ<br>បណ្តុះបណ្តាលពីការចិញ្ចឹមសត្វ ។ | |
| ព្រៃឈើថយចុះ | ៣ភូមិ | ការកាប់ព្រៃឈើអនាធិប | បង្ក្រាបបទល្មើសព្រៃឈើ | | -ពង្រឹងវិធានការណ៏គ្រប់គ្រងការពារ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | តេយ្យ<br>ការរានដីព្រៃធ្វើចំការច្រើន<br>-កំណើនប្រជាពលរដ្ឋ | ព្រៃឈើនៅគង់វង្ស | | - ផ្សព្វផ្សាយច្បាប់ព្រៃឈើ<br>- ដាំកូនឈើឡើងវិញ<br>- ពង្រឹងគណៈកម្មាការគ្រប់គ្រង | |
| សត្វព្រៃមានការថយចុះ | ៣ភូមិ | -ការបរបាញ់ខុសច្បាប់<br>-បំផ្លាញជំរកសត្វ<br>-ការប្រែប្រួលសង្គម | សត្វព្រៃកើនឡើង | | - ទប់ស្កាត់ការបរបាញ់ខុសច្បាប់<br>- ទប់ស្កាត បំផ្លាញជំរកសត្វ | |
| ផ្លូវលំក្រាលគ្រួសក្រហម | ៣ភូមិ | ផ្លូវលំបាកធ្វើដំណើរ | ងាយស្រួលក្នុងការធ្វើដំណើរ | | - ជួសជុលផ្លូវលំ<br>-សាងសង់ស្ពានឈើ<br>-សាងសង់លូកាត់ផ្លូវ | |
| សត្វឈឺច្រើន | ៣ភូមិ | -ខ្វះបច្ចេកទេសក្នុងការថែទាំសត្វ<br>- ខ្វះថ្នាំព្យាបាល,ការពារ<br>- ពេទ្យសត្វនៅមានកំរិតយល់ដឹង | -ផ្តល់បច្ចេកទេសក្នុងការថែទាំសត្វ<br>-ផ្តល់ថ្នាំព្យាបាលការពារ<br>- ពេទ្យសតមានកំរិតយល់ដឹងខ្ពស់ | | -បណ្តុះបណ្តាលច្ចេកទេសចិញ្ចឹមសត្វ<br>- ចាក់ព្យាបាល,ចាក់វ៉ាក់សាំងការពារ<br>- បណ្តុះបណ្តាលច្ចេកទេសដល់ពេទ្យសត្វ និងកសិករ ឱ្យមានការយល់ដឹង | |

| | | | | | | |
|---|---|---|---|---|---|---|
| គ្មានបង្គន់អនាម័យ | ៣ភូមិ | ខ្វះបង្គន់អនាម័យប្រើប្រាស់ | - មានបង្គន់អនាម័យប្រើប្រាស់ | | - ផ្តល់បង្គន់អនាម័យប្រើប្រាស់តាមក្រុម<br>-បង្កើតគណៈកម្មាការថែទាំ | |
| ខ្វះពូជគោល្អ | ៣ភូមិ | គ្មានថវិកាទិញ | ទិញពូជគោល្អៗ | | -ទិញពូជគោល្អៗយកមកប្រើប្រាស់ | |
| អំពើហឹង្សាក្នុងគ្រួសារ | ៣ភូមិ | -ជីវភាពមិនគ្រប់គ្រាន់<br>-ការប្រចណ្ឌ័<br>-សេពគ្រឿងញៀន | -គ្មានអំពើហឹង្សាក្នុងគ្រួសារ | | - ផ្សព្វផ្សាយពីច្បាប់អំពើហឹង្សាក្នុងគ្រួសារ តាមការសែត,វីដេអូ,រូបភាព | |
| ប្រជាជនឈឺច្រើន | ៣ភូមិ | -ខ្វះអនាម័យ<br>-ខ្វះថ្នាំបង្កា<br>-ហូបចុកមិនគ្រប់គ្រាន់ | -សុខភាពប្រជាជនប្រសើរឡើង | | -ចាក់វ៉ាក់សាំងការពារ<br>-ផ្តល់មុងជ្រលក់ថ្នាំ<br>-វគ្គអប់រំសុខភាព<br>-ពង្រឹងភ្នាក់ងារសុខភាពភូមិ | |
| ទិន្នផលស្រូវទាប | ៣ភូមិ | - ខ្វះពូជស្រូវទំនើបៗ<br>-ឧបករណ៏កសិកម្មទំនើបៗ<br>-ខ្វះបច្ចេកទេសដាំដុះ | ស្បៀងហូបគ្រប់គ្រាន់ | | -ផ្តល់ពូជស្រូវល្អៗ<br>-ផ្តល់បច្ចេកទេស | |

# ឧបសម្ព័ន្ធ ៤

## ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងវិស័យនៃការប្រើប្រាស់ដីធ្លីអនាគត

## កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ (តារាង)

| តម្រូវការនៃ ការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃ ការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀង នៅលើ ផែនទី |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ចង់អោយសត្វមានការកើនឡើង | -ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ សិរីមង្គល ស្រុកកូនមុំ ខេត្ត រតនគីរី | -ដោះស្រាយជីវភាពក្នុងគ្រួសារ | -បង្កើនការចិញ្ចឹមសត្វ | - ចាក់វ៉ាក់សាំងសត្វ<br>- បណ្តុះបណ្តាលពេទ្យសត្វ<br>- ផ្សព្វផ្សាយជំងឺផ្តាសសាយបក្សី<br>- ផ្តល់សត្វចិញ្ចឹមតាមគ្រួសារ | |
| ធ្វើដំណើរបានស្រួល | -ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ សិរីមង្គល ស្រុកកូនមុំ ខេត្ត រតនគីរី | -ផលិតផលកសិផលលក់បានថ្លៃ | -ពង្រឹងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន | - ជួសជុលផ្លូវលំ<br>-សាងសង់ស្ពានឈើ | |
| ចង់អោយផលិតផល កសិ | -ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ | ប្រជាពលរដ្ឋមានជីវភាព | ជំរុញវិស័យកសិកម្មរីក | - ផ្តល់ថ្នាំសំលាប់សត្វល្អិត | |

| | | | | | |
|---|---|---|---|---|---|
| ផលកើន | ២០០៨-២០១២ របស់ឃុំ សិរីមង្គល ស្រុកកូនមុំ ខេត្ត រតនគិរី | ធូធារ | ចំរើន | - ផ្តល់ពូជស្រូវទិន្នផលខ្ពស់<br>- ផ្តល់ពូជស្រូវឡើងទឹក<br>-បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម<br>- បណ្តុះបណ្តាលការធ្វើជីកំប៉ុស្ត៍<br>- ផ្តល់ពូជគោបាកូនកាត់<br>- ផ្តល់ធនាគាស្រូវ<br>-ផ្តល់ពូជឈើហូបផ្លែ<br>-ផ្តល់ពូជបន្លែ<br>-ផ្តល់ម៉ាស៊ីនបោកស្រូវ | |
| កាត់បន្ថយគ្រោះថ្នាក់ពេលសំរាល | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ សិរីមង្គល ស្រុកកូនមុំ ខេត្ត រតនគិរី | ស្ត្រីមានសុវត្ថិភាព និង សុខមាលភាព | បង្កើនមានសុវត្ថិភាព ដល់ស្ត្រី | - បណ្តុះបណ្តាលពេទ្យឆ្មប<br>- បណ្តុះបណ្តាលឆ្មបបូរាណ<br>- សាងសង់ប៉ុស្តិ៍សុខភាពសមរម្យ<br>-បង្កើតបណ្តាញពិនិត្យសុខភាពតាមភូមិ<br>-បណ្តុះបណ្តាលការពន្យាកំណើត<br>-ផ្តល់ការចាក់វ៉ាក់សាំង៧មុខ<br>-បណ្តុះបណ្តាលពីអាហារូបត្ថម្ភ | |

| | | | | | |
|---|---|---|---|---|---|
| ចង់អោយកុមារមាន ចំណេះដឹង | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ សិរីមង្គល ស្រុកកូនមុំ ខេត្ត រតនគិរី | ធនធានមនុស្សក្នុងឃុំកើន ឡើង | ជំរុញកុមារអោយចូល រៀន | - សាងសង់សាលាមតេយ្យ<br>- ផ្តល់គ្រូមតេយ្យសិក្សា | |
| កាត់បន្ថយជំងឺគ្រុនឈាម និង ជំងឺគ្រុនចាញ់ | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ សិរីមង្គល ស្រុកកូនមុំ ខេត្ត រតនគិរី | គ្រួសារមានសុខភាពមិនខាត បង់ប្រាក់កាស | បង្កើនការការពារជំងឺ គ្រុនឈាម និង ជំងឺគ្រុនចាញ់ | - ផ្តល់មុងជ្រលក់ថ្នាំ<br>-ផ្សព្វផ្សាយជំងឺគ្រុនឈាម គ្រុនចាញ់<br>- ផ្តល់ថ្នាំអាបែត | |
| ចង់មានអនាម័យ និង ការប្រើប្រាស់ទឹកស្អាត | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ សិរីមង្គល ស្រុកកូនមុំ ខេត្ត រតនគិរី | មានអនាម័យ និង ទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ | បង្កើនការប្រើប្រាស់ទឹក ស្អាតនិងថែទាំសុខភាព | - ជីកស្រះទឹកស្អាត<br>-ខួងអណ្តូងស្នប់<br>-ផ្តល់ធើងជំរោះទឹក<br>-បណ្តុះបណ្តាលការប្រើប្រាស់ទឹក<br>-ផ្តល់បង្គន់អនាម័យ | |
| ចង់អោយព្រៃឈើកើន ឡើង | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ សិរីមង្គល ស្រុកកូនមុំ | ងាយស្រួលក្នុងការប្រើ ប្រាស់ | បង្កើនការថែរក្សាព្រៃ ឈើ | - ផ្សព្វផ្សាយច្បាប់ព្រៃឈើ<br>- បង្កើតថ្នាលបណ្តុះកូនឈើ<br>- ផ្តល់សំភារៈបច្ចេកទេសបណ្តុះ | |

| | | | | | |
|---|---|---|---|---|---|
| | ខេត្ត រតនគិរី | | | កូនឈើ | |
| ចង់អោយធនធានជលផលកើន | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំសិរីមង្គល ស្រុកកូនមុំ ខេត្ត រតនគិរី | មានម្ហូបអាហារគ្រប់គ្រាន់ | បង្កើនធនធានជលផល | - ពង្រឹងគណៈកម្មការការពារអន្លង់<br>- បង្កើតក្រុមល្បាត<br>-ដកហូតឧបករណ៏នេសាទខុសច្បាប់<br>- ផ្សព្វផ្សាយការនេសាទត្រីនៅរដូវត្រីពង | |
| ចង់បានដីបំរុងសំរាប់គ្រួសារថ្មីធ្វើស្រែចំការ | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំសិរីមង្គល ស្រុកកូនមុំ ខេត្ត រតនគិរី | មានដីបំរុងសំរាប់គ្រួសារថ្មីធ្វើស្រែចំការ | រៀបចំដីបំរុងសំរាប់ស្រែចំការ | - ផ្តល់បណ្ណ័កម្មសិទ្ធិដីធ្លី<br>- ផ្សព្វផ្សាយច្បាប់ភូមិបាល<br>- រៀបចំផែនការប្រើប្រាស់ដី<br>- បែងចែកដីដល់គ្រួសារក្រីក្រ | |
| ចង់អោយស្ត្រី និង កុមារសុវត្ថិភាព | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំសិរីមង្គល ស្រុកកូនមុំ ខេត្ត រតនគិរី | | ទប់ស្កាត់ការជួញដូរស្ត្រី កុមារ | - ផ្សព្វផ្សាយការជួញដូរស្ត្រី កុមារ | |
| ចង់អោយអាជ្ញាធរភូមិ ឃុំ | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ | លើកកំពស់ការអនុវត្ត | បង្កើនសមត្ថភាព | -បណ្តុះបណ្តាលការកសាងផែន | |

| | | | | | |
|---|---|---|---|---|---|
| មានចំណេះដឹងនិងសន្តិសុខ | ២០០៨-២០១២ របស់ឃុំ សិរីមង្គល ស្រុកកូនមុំ ខេត្ត រតនគិរី | ការ ងារនៅមូលដ្ឋាន | អនុវត្តការងារនៅ មូលដ្ឋាន | ការ<br>- បណ្តុះបណ្តាលការងាររដ្ឋបាល<br>-ផ្តល់មធ្យោបាយធ្វើដំណើរដល់ គ. ជ. ថ<br>- បណ្តុះបណ្តាលពីគ្រឿងញៀន<br>- បង្រ្កាបល្បែងស៊ីសង<br>- ផ្សព្វផ្សាយច្បាប់អំពើហឹង្សា<br>- ផ្តល់កុំព្យូទ័រ<br>-បណ្តុហបណ្តាលពីការប្រើប្រាស់ កុំព្យូទ័រ<br>- សាងសង់សាលាឃុំ<br>-សាងសង់សាលាឆទាន | |

# ឧបសម្ព័ន្ធ ៥

## បញ្ជីគំរោង ឬសកម្មភាពសំខាន់របស់ឃុំ ក្នុងរយៈពេល ១៥ឆ្នាំ

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី១ [១] | ៥ឆ្នាំទី២ [២] | ៥ឆ្នាំទី៣ [៣] | |
| ២.៦.១. | គំរោងផ្នែកហេដ្ឋរចនាសម្ព័ន្ធ | | | | | | |
| | **២.៦.១.១. គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត** | | | | | | |
| | **១.១. ផ្លូវថ្នល់** | | | | | | |
| | ១.១.១. សាងសង់ផ្លូវលំ | ២ | ខ្សែ | ១ | ១ | | |
| | ១.១.២. ជួសជុលផ្លូវលំ | ១ | ខ្សែ | | ១ | | |
| | ១.១.៣. សាងសង់ស្ពានឈើ | ៥ | កន្លែង | ២ | ២ | ១ | |
| | ១.១.៤. សាងសង់លូកាត់ផ្លូវ | ១៨ | កន្លែង | ៦ | ៦ | ៦ | |
| | **១.២. ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត** | | | | | | |
| | ១.៣.១. ចំនួន ស្ពានថ្ម | ២ | កន្លែង | | ១ | ១ | |
| | ១.៣.២. ចំនួនលូឆ្លងផ្លូវ | ១២ | កន្លែង | ៥ | ៤ | ៣ | |

[១] - ៥ឆ្នាំទី១ (២០០៨-២០១២): បញ្ចូលគំរោងទាំងអស់របស់ **CDP** ឆ្នាំ ២០០៨-២០១២ រួមទាំងគំរោងផ្នែកប្រើប្រាស់ដីដែលបានបង្កើតក្នុង **CLUP** ផងដែរ (៥ ឆ្នាំទី១)

[២] - ៥ឆ្នាំទី២ (២០១៣-២០១៧): គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្ត (៥ ឆ្នាំទី២)

[៣] - ៥ឆ្នាំទី២ (២០១៨-២០២២): គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្តទៀត (៥ ឆ្នាំទី៣)

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១.៣.៣. ផ្សេងៗ | | | | | | |
| | **២.៦.១.២. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មផ្សេងៗ** | | | | | | |
| | ២.៦.១.២.១. ការសិក្សា និងអប់រំ | | | | | | |
| | ២.៦.១.២.២. សាលាមត្តេយ្យ | ០២ | អាគារ | ១ | ១ | | |
| | ២.៦.១.២.៣. សាលាបឋមសិក្សា | ០៣ | អាគារ | ១ | ១ | ១ | |
| | ២.៦.១.២.៤. សាលាមធ្យមសិក្សា | ០៤ | អាគារ | ១ | ២ | ២ | |
| | ២.៦.១.២.៥. ផ្តល់គ្រូគ្រប់ក៏រិត | ០៤ | កន្លែង | ៤ | | | |
| | **២.៦.១.៣. សុខភាព និងអនាម័យ** | | | | | | |
| | ២.៦.១.៤. បុស្តិ៍សុខភាព | ០១ | កន្លែង | ១ | | | |
| | ២.៦.១.៥. ប៉ុស្តិ៍សុខភាពតាមភូមិ | ៣ | កន្លែង | ១ | ១ | ១ | |
| | ២.៦.១.៦. ផ្តល់ធើងចំរោះទឹកស្អាត | ៣២៨ | ចំនួន | ១០០ | ១០០ | ១២៨ | |
| | ២.៦.១.៧. ស្រះទឹកស្អាត | ២០ | ស្រះ | ១០ | ៥ | ៥ | |
| | ២.៦.១.៨. អណ្តូងទឹកស្អាត | ២០ | អណ្តូង | ១០ | ៥ | ៥ | |
| | ២.៦.១.៩. ផ្តល់បង្គន់អនាម័យ | ១៧ | កន្លែង | ៥ | ៦ | ៦ | |
| | **២.៦.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់** | | | | | | |
| | ២.៦.១.៤.១. វគ្គបណ្តុះបណ្តាលការងាររដ្ឋបាលនិង អភិបាលកិច្ចដល់សមាជិក គ. ជ. ថ | ៣ | លើក | ១ | ១ | ១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.១.៤.២. ទប់ស្កាត់ការហូរចូល នូវគ្រឿងញៀន | ៥ | លើក | ១ | ២ | ២ | |
| | ២.៦.១.៤.៣. ពង្រឹងមន្ត្រីប៉ុស្តិ៍រដ្ឋបាលឃុំ | ៣ | លើក | ១ | ១ | ១ | |
| | ២.៦.១.៤.៤. ពង្រឹងប្រព័ន្ធកសាងផែនការតាមមូលដ្ឋាន | ៣ | លើក | ១ | ១ | ១ | |
| | **២.៦.១.៥. កន្លែងគោរពបូជា** | | | | | | |
| | ២.៦.១.៥.១. ទីកន្លែងសាការៈបូជា | | | | | | |
| | ២.៦.១.៥.២. វត្តអារាម | ២ | កន្លែង | ១ | ១ | | |
| | ២.៦.១.៥.៣. សាលាឆទាន | ២ | កន្លែង | | ១ | ១ | |
| ២.៦.២ | គំរោងផ្នែកប្រើប្រាស់ដីធ្លី | | | | | | |
| | **២.៦.២.១. គំរោងប្រើប្រាស់ដីតាមវិស័យធំៗ** | | | | | | |
| | ២.៦.២.១.១. ដីកាពារដែនជំរកសត្វព្រៃត្រើយ ម្ខាងទន្លេ | | ហិកតា | | | | |
| | ២.៦.២.១.២. ដីតំបន់ប្រើប្រាស់ច្រើនយ៉ាង | | ហិកតា | | | | |
| | ២.៦.២.១.៣. ដីសម្បទានសង្គមកិច្ច | | ហិកតា | | | | |
| | **២.៦.២.២. គំរោងប្រើប្រាស់ដីលក្ខណៈសហគមន៍ភូមិ-ឃុំ** | | | | | | |
| | ២.៦.២.២.១. ដីភូមិ | | ហិកតា | | | | |
| | ២.៦.២.២.២. ដីវាលកប់ខ្មោច | | ហិកតា | | | | |
| | ២.៦.២.២.៣. ដីវាលស្រែ | | ហិកតា | | | | |
| | ២.៦.២.២.៤. ដីចំការដំណាំរយៈពេលខ្លី | | ហិកតា | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.២.២.៥. ដីចំការដំណាំឈើហូបផ្លែ | | ហិកតា | | | | |
| | ២.៦.២.២.៦. ផ្សេងៗ | | | | | | |
| | **២.៦.២.៣. គំរោងផ្នែកបង្កើនជំនាញ និងមុខរបរ** | | | | | | |
| | ២.៦.២.៣.១. វគ្គបណ្ដុះបណ្ដាលអំពីការធ្វើស្រែបង្កើនរដូវ | ៦ | លើក | ៣ | ៣ | | |
| | ២.៦.២.៣.២. វគ្គបណ្ដុះបណ្ដាល អំពីការប្រើប្រាស់ជីធម្មជាតិ | ៦ | លើក | ៣ | ៣ | | |
| | ២.៦.២.៣.៣. វគ្គបណ្ដុះបណ្ដាល អំពីការកែប្រែគុណភាពដី | ៣ | លើក | ១ | ១ | ១ | |
| | ២.៦.២.៣.៤. វគ្គបណ្ដុះបណ្ដាលដល់ឆ្មបបុរាណ | ១ | លើក | ១ | | | |
| | ២.៦.២.៣.៥. វគ្គបណ្ដុះបណ្ដាលពេទ្យឆ្មប | ៦ | លើក | ២ | ២ | ២ | |
| | ២.៦.២.៣.៦. វគ្គបណ្ដុះបណ្ដាលពន្យាកំណើត | ១២ | លើក | ៤ | ៤ | ៤ | |
| | ២.៦.២.៣.៧. វគ្គបណ្ដុះបណ្ដាលការចាក់វ៉ាក់សាំង៧មុខដល់កុមារ | ១២ | លើក | ៤ | ៤ | ៤ | |